NGO-CEDAW

២០២០

# របាយការណ៍តាមដាន ការអនុវត្តអនុសញ្ញា ស៊ីដ សម្រាប់ប្រទេសកម្ពុជា



# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ រៀបចំឡើងដោយ NGO-CEDAW ក្រោមការសហការពីសំណាក់អង្គការសង្គមស៊ីវិលជាសមាជិក និងអង្គការដៃគូមួយចំនួន។ NGO-CEDAW សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ អង្គការអាក់សិនអេតកម្ពុជា, អង្គការបន្ទាយស្រី, អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍ (ឆេក), សហភាពការងារកម្ពុជា, គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល), អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា, អង្គការក្លាហាន, សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធមនុស្ស (លីកាដូ), គណៈកម្មាធិការអព្យាក្រឹតនិងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវ (និកហ្វិក), អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (រ៉ាក់), មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, មជ្ឈមណ្ឌលសាមគ្គីភាព (SC) និងមជ្ឈមណ្ឌលធនធានស្ត្រី ដែលបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការផ្តល់ធាតុចូលសម្រាប់របាយការណ៍នេះ។

NGO-CEDAW ក៏សូមថ្លែងអំណរគុណដល់ សហភាពអឺរ៉ុប (EU) អង្គការជំនួយព្រះវិហារដាណឺម៉ាក់ (DCA) និងមូលនិធិហេនរេចបូលស្ទីហ្វទង់ (HBF) ដែលបានគាំទ្រថវិកាសម្រាប់ការរៀបចំរបាយការណ៍នេះ។

This publication was produced with the financial support of the European Union. Its contents are the sole responsibility of NGO-CEDAW and does not necessarily reflect the views of the European Union.

# ទិដ្ឋភាពទូទៅនៅឆ្នាំ២០២០

ឆ្នាំ២០២០ បាននាំមកឱ្យប្រទេសកម្ពុជានូវបញ្ហាប្រឈមជាច្រើនសម្រាប់វិស័យសិទ្ធិស្ត្រី ទន្ទឹមនឹងនោះ ក៏មានឱកាសប្រសើរឡើងនៃកិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលក្នុងការស្វែងរកដំណោះស្រាយ ចំពោះបញ្ហាប្រឈមទាំងនោះ។

បញ្ហាប្រឈមដែលលេចធ្លោបំផុត គឺទាក់ទងនឹង សុខភាព ការអប់រំ និងការលំបាកផ្នែកសេដ្ឋកិច្ច ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលធ្វើឱ្យស្ត្រីនិងអ្នកស្រលាញ់ភេទដូចគ្នា ប្រឈមនឹងការលំបាកនៅក្នុងអត្រាមួយដែលគ្មានសមាមាត្រ។ បន្ថែមពីលើនេះទៀត រដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីព្រាងនិង/ឬបានអនុម័តគោលនយោបាយថ្មីៗមួយចំនួនទាក់ទងនឹងយេនឌ័រ ដែលអង្គការសង្គមស៊ីវិល (រួមបញ្ចូលទាំង NGO-CEDAW និងបណ្តាញរបស់ខ្លួន) បានរួមចំណែកផ្តល់ធាតុចូលជាច្រើន។ ទោះជាយ៉ាងណា នៅតែមានឧទាហរណ៍ជាច្រើនដែលបង្ហាញពីការរឹតត្បឹតទៅលើការប្រើប្រាស់សេរីភាពផ្លូវភេទ និងសេរីភាពនៃការសម្តែងចេញនូវបូរណភាពរាងកាយរបស់ស្ត្រី។

# ការផ្តល់ធាតុចូលលើគោលនយោបាយរបស់រដ្ឋាភិបាល

ឆ្នាំនេះ បានចាប់ផ្តើមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការសម្រេចបញ្ចប់គោល-នយោបាយជាច្រើន ដែលជះឥទ្ធិពលដោយផ្ទាល់ទៅលើស្ត្រី តាមរយៈការអញ្ជើញក្រុមស្ត្រីមួយចំនួនឱ្យចូលរួមពិគ្រោះយោបល់ទៅលើ ផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣) (NAPVAW3) [1] នារីរតនៈទី៥ [2] និងគោលនយោបាយថ្នាក់ជាតិដំបូងបំផុតស្តីពីសមភាពយេនឌ័រ [3] ។ នៅពេលដំបូង រដ្ឋាភិបាលគ្រាន់តែចង់ឮមតិយោបល់បន្តិចបន្តួច នៅក្នុង រយៈពេលមួយសប្តាហ៍តែប៉ុណ្ណោះ ក៏ប៉ុន្តែអង្គការសង្គមស៊ីវិលនិងដៃគូអភិវឌ្ឍន៍ បានធ្វើការតស៊ូមតិដោយជោគជ័យក្នុងការអនុញ្ញាតឱ្យមានពេលវេលាបន្ថែមទៀត ដើម្បីឱ្យអង្គការសង្គមស៊ីវិលអាចចូលរួមចំណែកកាន់តែមានអត្ថន័យទៅលើផែនការទាំងអស់នោះ។ បន្ថែមពីលើនេះ ក្រសួងកិច្ចការនារីបានកំពុងរៀបចំបង្កើតឡើងនូវការធ្វើបច្ចុប្បន្នភាពសទ្ទានុក្រមយេនឌ័រដើម្បីឱ្យភ្នាក់ងាររដ្ឋាភិបាលអាចមានវាក្យសព្ទទូលំទូលាយគ្រប់ជ្រុងជ្រោយមួយ និងមានភាពស៊ីចង្វាក់សម្រាប់ដោះស្រាយបញ្ហាទាក់ទងនឹងយេនឌ័រ។ ទោះបីជាធាតុចូលមួយចំនួន ត្រូវបានដាក់បញ្ចូលទៅក្នុងអត្ថបទគោល-នយោបាយចុងក្រោយក៏ពិតមែន ក៏នៅតែមានគម្លាតមួយចំនួនរវាងសកម្មភាពដែលតម្រូវឱ្យមានការអនុលោមទៅតាមអនុសញ្ញា ស៊ីដ ទៅនឹងគោលនយោបាយដែលបានធ្វើបច្ចុប្បន្នភាពទាំងនេះ។ ជាពិសេស សទ្ទានុក្រម ដែលបានបញ្ចូលនៅក្នុង NAPVAW3 មានភាពមិនស៊ីចង្វាក់មួយចំនួនទៅនឹងស្តង់ដារអន្តរជាតិនៅឡើយ តែទោះជាយ៉ាងណាក៏ដោយ ក៏មានកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការកែតម្រូវបញ្ហានេះ នៅក្នុងឯកសារសទ្ទានុក្រមយេនឌ័រវិញដែរ។

[1] NAPVAW3 was adopted in October 2020, and can be found online in Khmer and English at https://drive.google.com/drive/folders/10FVZsah-iUPn73IF9t7vHCV_GUAsy5RX
[2] https://www.mowa.gov.kh/en/policiesNeary Rattanak V was adopted in June 2020.
[3] The NPGE and gender terminology remained in draft form throughout 2020.

បន្ថែមពីលើនេះ ទោះបីជា NAPVAW3 ដាក់បញ្ចូលគោលដៅជាសកម្មភាពក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារក៏ដោយ ក៏ឯកសារនេះមិនបានបញ្ជាក់ឱ្យច្បាស់ថារដ្ឋាភិបាលនឹងឆ្លើយតបចំពោះអនុសាសន៍របស់គណៈកម្មាធិការទទួលបន្ទុកលើអនុសញ្ញា ស៊ី ដ តាមរយៈការដាក់ជូនរបាយការណ៍តាមដាន ស្តីពីការធ្វើវិសោធនកម្មនៃច្បាប់នេះ និងការបង្កើតផែនការសកម្មភាពដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៣២៥ របស់អង្គការសហប្រជាជាតិដោយរបៀបណានោះទេ។

# វីរុសកូរ៉ូណានិងផលប៉ះពាល់មកលើកម្ពុជា

ក្នុងខែកុម្ភៈឆ្នាំ២០២០ ក្តីបារម្ភអំពីការរីករាលដាលនៃវីរុសកូរ៉ូណា ធ្វើឱ្យមានការកាត់បន្ថយសកម្មភាពជាច្រើន រួមទាំងការលុបចោលសន្និសីទទីក្រុងប៉េកាំង (BeiJing+25) របស់គណៈកម្មាធិការទទួលបន្ទុកស្ថានភាពស្ត្រី (CSW) ដែលត្រូវរៀបចំឡើងនៅក្នុងទីក្រុងញូវយ៉កនៅសប្តាហ៍ទីមួយ ក្នុងខែមីនា ឆ្នាំ២០២០ ហើយដែលអង្គការ NGO-CEDAW និងសមាជិកអង្គការសង្គមស៊ីវិលកម្ពុជាដទៃទៀត បានរៀបចំផែនការបញ្ជូន តំណាងទៅចូលរួមរួចរាល់ហើយ។ អង្គការជាច្រើនបានចាប់ផ្តើមលុបចោលសិក្ខាសាលានានា និងចាប់ផ្តើមធ្វើការទាក់ទងគ្នាពីចម្ងាយ។

នៅចុងខែមីនា ដៃគូអន្តរជាតិជាច្រើនបានចាកចេញពីប្រទេសកម្ពុជាជាបណ្តោះអាសន្ន ហើយសកម្ម-ភាពបណ្តុះបណ្តាល និងកិច្ចប្រជុំជាមួយរដ្ឋាភិបាលភាគច្រើន ត្រូវបានលើកពេលដោយគ្មានកាលកំណត់ ឬត្រូវរៀបចំឡើងតាមប្រព័ន្ធអនឡាញវិញ។ សាលារៀនត្រូវបានបិទនៅទូទាំងប្រទេស។ រោង-ចក្រជាច្រើន ជាពិសេសក្នុងវិស័យកាត់ដេរនិងស្បែកជើង ដែលពឹងផ្អែកទៅលើការបញ្ជាទិញពីបរទេសត្រូវបិទទ្វារ ឬកាត់បន្ថយផលិតកម្ម ដែលបណ្តាលឲ្យកម្មករច្រើនជាង ១៥០.០០០នាក់ បាត់បង់ការងារជាអចិន្ត្រៃយ៍ ឬត្រូវព្យួរការងារ។ [4] ការផ្តល់ទិដ្ឋាការទេសចរណ៍ក៏មិនមានទៀតដែរ ហើយព្រំដែនជាច្រើននៅក្នុងតំបន់ត្រូវបានបិទ។ អាជីវកម្មដែលពឹងផ្អែកទៅលើការធ្វើដំណើរ ឬការទាក់ទងជិតស្និទ្ធ ជាមួយអតិថិជននោះ បានទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ឬត្រូវបានបិទទ្វារ។ អាជីវកម្មទាំងនេះ រួមមាន បារ កន្លែងម៉ាស្សា រោងភាពយន្ត ភ្នាក់ងារទេសចរ ផ្ទះសំណាក់ សណ្ឋាគារ និងភោជនីយដ្ឋាន។ វិស័យសំណង់ ក៏មានការធ្លាក់ចុះដែរ។

រាជរដ្ឋាភិបាលមិនបានដាក់ប្រទេសក្នុងគ្រាអាសន្ន ឬបិទប្រទេសទាំងស្រុងក្នុងឆ្នាំ២០២០ ដូចប្រទេសផ្សេងៗទៀតនោះទេ ពីព្រោះរហូតដល់ពេលថ្មីៗនេះ មិនមានការរីករាលដាលតាមសហគមន៍ច្រើននោះទេ។ ដូច្នេះហើយរហូតមកទល់ពេលនេះ នៅមិនទាន់មានទិន្នន័យគ្រប់គ្រាន់បង្ហាញពីវិសាលភាពនៃអំពើហិង្សាក្នុងគ្រួសារដែលកើតឡើង ដោយសារតែស្ត្រីត្រូវបានបង្ខំឱ្យស្នាក់នៅក្នុងផ្ទះជាមួយជនប្រព្រឹត្តនោះទេ។ ក៏ប៉ុន្តែមានទិន្នន័យដែលបានបង្ហាញថា ស្ត្រីពិតជាទទួលរងនូវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចច្រើនជាងគេ ដោយសារតែជំងឺកូវីដ-១៩ បានបណ្តាលឲ្យពួកគេបាត់បង់ការងារ។ កម្មករចំណាកស្រុកដែលធ្វើការនៅបរទេស ត្រូវបានបង្ខំឱ្យត្រឡប់មកប្រទេសកម្ពុជាវិញ ដោយគ្មានការងារធ្វើ។ ស្ត្រីកម្ពុជាដែលធ្វើការក្នុងប្រទេសកម្ពុជា រួមទាំងស្ត្រីដែលផ្លាស់ប្តូរទីលំនៅដើម្បីស្វែងរកការងារ

[4] https://www.business-humanrights.org/de/neuste-meldungen/cambodia-450-garment-factories-suspend-their-operations-affecting-over-15000-workers-due-to-covid-19-eus-eba-withdrawal/

ក្នុងស្រុកជាច្រើននាក់ដែរនោះ បានទទួលរងភាពគ្មានការងារធ្វើក្នុងកម្រិតខ្ពស់មួយ។ បញ្ហានេះពិតជាជាក់ស្តែងណាស់ ដោយសារតែមានស្ត្រីច្រើនធ្វើការនៅក្នុងវិស័យកាត់ដេរ បដិសណ្ឋារកិច្ច សេវាកម្មភោជនីយដ្ឋាន និងសំណង់ នៅក្នុងសេដ្ឋកិច្ចកម្ពុជា។ ការកាត់បន្ថយការងារនៅក្នុងឧស្សាហកម្មទាំងអស់នេះ បានបង្កផលប៉ះពាល់ដល់ស្ត្រីយ៉ាងខ្លាំង ដោយពួកគេត្រូវបង្ខំឲ្យចាកចេញពីវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ ចូលទៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង/ឬ ត្រូវជាប់បំណុល។ គំនាបផ្នែកសេដ្ឋកិច្ចបែបនេះ ក៏ជាកត្តាមួយដែលគេបានដឹងថា រួមចំណែកឲ្យមានអំពើហិង្សាផ្អែកលើយេនឌ័រ តាមរយៈការជំរុញឲ្យស្ត្រីបន្តរស់នៅក្នុងស្ថានភាពហិង្សា ដោយសារតែហេតុផលហិរញ្ញវត្ថុ ឬក្លាយជាជនងាយរងគ្រោះខ្លាំងចំពោះការកេងប្រវ័ញ្ច។

ក្នុងឱកាសយុទ្ធនាការ១៦ថ្ងៃនៅចុងឆ្នាំ២០២០នេះ អង្គការសង្គមស៊ីវិលចំនួន៩ បានចេញសេចក្តីថ្លែងការណ៍រួមមួយ អំពាវនាវឲ្យមានការចាត់វិធានការជាក់លាក់ ក្នុងការដោះស្រាយតម្រូវការរបស់កម្មករជាស្ត្រីដែលកំពុងតែប្រឈមជាមួយការលំបាកទាំងនេះ ដោយសារតែជំងឺកូវីដ-១៩ ។ អនុសាសន៍ទាំងអស់នោះ រួមមានដូចជា៖ ការផ្តល់ថវិកាប្រចាំខែចំនួន ៤០ដុល្លារ ដល់កម្មករដែលបាត់បង់ការងារ, សម្រួលការចុះបញ្ជីរបបសន្តិសុខសង្គម ដើម្បីជួយឲ្យទទួលបានអត្ថប្រយោជន៍ផ្នែកសុខភាពនិងហិរញ្ញវត្ថុ, ផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៩០ ស្តីពីការលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ និងការបៀតបៀនក្នុងពិភពការងារ (C190) របស់អង្គការអន្តរជាតិខាងការងារ (ILO) ដើម្បីដោះស្រាយអំពើហិង្សានិងការបៀតបៀនក្នុងពិភពការងារ, ពង្រឹងការអនុវត្តច្បាប់ឲ្យបានតឹងរឹងប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ, ដោះស្រាយវិវាទដីធ្លីរយៈពេលវែង, ដោយរួមបញ្ចូលទាំងដាក់បញ្ចូលសមាស-ភាពកសិករទៅក្នុងកម្មវិធីកិច្ចគាំពារសង្គម, តម្រូវឲ្យវិស័យឯកជនបង្កើតកញ្ចប់ថវិកាសង្គ្រោះបន្ទាន់មួយចំនួន ដើម្បីគាំទ្រដល់កម្មករដែលត្រូវបានបញ្ឈប់ពីការងារក្នុងវិស័យវាយនភ័ណ្ឌ និងស្បែកជើង។ បន្ថែមពីលើនេះទៀត ការបិទសាលារៀនស្ទើរតែពេញមួយឆ្នាំ២០២០នោះ ធ្វើឲ្យឪពុកម្តាយ ដ៏ច្រើនលើសលុប ជាពិសេសគឺស្ត្រីដែលជាម្តាយត្រូវនៅផ្ទះ និងបាត់បង់ប្រាក់ចំណូលពីការងារ ហើយត្រូវរ៉ាប់រងនូវបន្ទុកការងារដែលមិនមានប្រាក់កម្រៃ ដូចជាការងារថែទាំនិងអប់រំកូននៅផ្ទះជាច្រើនម៉ោងបន្ថែមទៀត។

ស្ត្រីនិគមជនភាគតិច រួមទាំងស្ត្រីជនជាតិខ្មែរឥស្លាម ពើបប្រឈមនឹងការកើនឡើងនៃការរើសអើង នៅពេលវិលត្រឡប់មកផ្ទះវិញ ក្រោយពីបានបញ្ចប់ការងារជាកម្មករការងារតាមផ្ទះ ឬបន្ទាប់ពីបានចូលរួមពិធីបុណ្យសាសនារបស់ខ្លួនដែលមានការជួបជុំលក្ខណៈទ្រង់ទ្រាយធំ ហើយបន្ទាប់មកត្រូវបានធ្វើតេស្តរកឃើញថាមានផ្ទុកជំងឺកូវីដ-១៩។ ដំបូងឡើយ នៅក្នុងរបាយការណ៍របស់រដ្ឋាភិបាលអំពីករណីជំងឺកូវីដ-១៩នេះ បានបង្ហាញព័ត៌មានអំពីជាតិសាសន៍បុគ្គលដែលបង្កឱ្យមានផ្ទត់គំនិតអវិជ្ជមានទៅលើជនជាតិខ្មែរឥស្លាមថា ជាមនុស្សដែលកខ្វក់ ឬមានជំងឺកូវីដ-១៩។

ស្ត្រីដែលមានពិការភាព ក៏ជួបប្រឈមនឹងការលំបាកជាពិសេសមួយចំនួន នៅក្នុងកំឡុងពេលនៃការរីករាលដាលជំងឺកូវីដនេះដែរ។ របាយការណ៍ស្ទង់មតិមួយ ដែលធ្វើឡើងក្នុងខែឧសភាឆ្នាំ២០២០ ទៅលើម្ចាស់អាជីវកម្មជាស្ត្រីចំនួន១៩នាក់ ដែលជាអ្នកមានពិការភាពផ្នែករាងកាយបានបង្ហាញថា ស្ថាន-ភាពតានតឹងក្នុងចិត្តរបស់ពួកគេមានការកើនឡើង ហើយពួកគេមានការបារម្ភអំពីហិរញ្ញវត្ថុរបស់ខ្លួន ហើយម្ចាស់អាជីវកម្មជាច្រើននោះ បានខាតបង់ប្រាក់របស់ខ្លួនរួចទៅហើយ នៅក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺនេះ ។ [5]

[5] Agile Development Group, “Rapid Research – Report: Impact of COVID-19 on Women Entrepreneurs with Disabilities in Cambodia,” May 2020.

# ការបង្ក្រាបទៅលើសិទ្ធិផ្លូវភេទនិងការសម្តែងចេញនូវជម្រើសនៃបូរណភាពរាងកាយរបស់ស្ត្រី

រដ្ឋាភិបាលកម្ពុជាមានគោលនយោបាយចម្បងចំនួន២ ដែលវាយប្រហារដោយផ្ទាល់ទៅលើការសម្តែងចេញនូវជម្រើសនៃបូរណភាពរាងកាយរបស់ស្ត្រីនៅក្នុងឆ្នាំ២០២០។ ទីមួយ គឺបង្កើតឡើងនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលសម្តេចនាយករដ្ឋមន្ត្រី បានថ្លែងស្តីបន្ទោសទៅលើសម្លៀកបំពាក់របស់ស្ត្រីថា ជាមូលហេតុបង្កឱ្យមានករណីអំពើហិង្សាផ្អែកលើយេនឌ័រ។ សម្តេចនាយករដ្ឋមន្ត្រីបានអំពាវនាវឲ្យមានការចាត់វិធានការ និងកោះហៅស្ត្រីទៅទទួលការអប់រំ និងឬបិទគណនីហ្វេសបុករបស់ស្ត្រីរូបណាដែលស្លៀកសម្លៀកបំពាក់បញ្ចេញសាច់ ឬបង្ហាញកាយវិការដែលអាចនាំឲ្យមានការរំញោចផ្លូវភេទ ដើម្បីលក់ផលិតផលនៅលើទំព័រហ្វេសប៊ុករបស់ខ្លួន។ ទន្ទឹមនេះដែរ គេមិនឃើញមានការលើកឡើងអំពីអាកប្បកិរិយាអសីលធម៌ ឬអាកប្បកិរិយាដែលជាបទល្មើសព្រហ្មទណ្ឌរបស់បុរសដែលជាជនប្រព្រឹត្តអំពើហិង្សានិងការបៀតបៀនផ្អែកលើយេនឌ័រនោះទេ។ នៅក្នុងរយៈពេល ២-៣ថ្ងៃក្រោយពីការថ្លែងសុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី អ្នកប្រើប្រាស់បណ្តាញសង្គមដើម្បីធ្វើអាជីវកម្មដែលជាស្ត្រី ឬជាស្ត្រីដែលផ្លាស់ប្តូរយេនឌ័រមួយចំនួន ត្រូវបានកម្លាំងនគរបាលឃាត់ខ្លួន និងនាំយកទៅ “អប់រំ” ក្នុងនោះមានស្ត្រីម្នាក់ត្រូវបាន ចោទប្រកាន់ពីបទល្មើសទាក់ទងទៅនឹងការបង្ហាញរូបភាព ឬវីដេអូអាសអាភាស ក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទៅវិញ។

អង្គការសង្គមស៊ីវិល បានដាក់ចេញនូវសេចក្តីថ្លែងការណ៍រួមជំទាស់ទៅលើកសកម្មភាពទាំងអស់នេះថា ជាការរើសអើងផ្អែកលើយេនឌ័រ។

ភាពមិនច្បាស់លាស់នៃខ្សែបន្ទាត់រវាងលំហសាធារណៈនិងលំហឯកជន បន្តក្លាយទៅជាបញ្ហាមួយដោយសារតែអាជ្ញាធរបន្តអនុវត្តដាក់ទោសទណ្ឌទៅលើ ស្ត្រីពាក់ព័ន្ធនឹងការផ្សព្វផ្សាយតាមប្រព័ន្ធហ្វេសប៊ុក ទាំងពួកគេមិនមានការរំលោភបំពានទៅលើច្បាប់ណាមួយជាក់លាក់នោះទេ។ គណៈកម្មាធិការ នៃអង្គការសហប្រជាជាតិទទួលបន្ទុកលើអនុសញ្ញា ស៊ី ដ បានផ្តល់អនុសាសន៍រួចហើយថា ច្បាប់ឬគោលនយោបាយណាដែលមានខ្លឹមសារផ្ទុយពីអនុសញ្ញានេះ ត្រូវតែនិរាករណ៍ ដោយសារតែវាជាការរើសអើងទៅលើស្ត្រីតាមរយៈការដាក់ទណ្ឌកម្ម ជាពិសេសកើតមានឡើងភាគច្រើនទៅលើស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ប៉ុន្តែមិនបានដាក់ទណ្ឌកម្មទៅលើអតិថិជនជាបុរសនោះទេ។ ទោះបីជាយ៉ាងនេះក្តី ក៏អាជ្ញាធរបានបង្ហាញពីបំណងរបស់ខ្លួន ក្នុងការចោទប្រកាន់ស្ត្រីម្នាក់ពីបទអូសទាញ ដោយផ្អែកតែទៅលើការផ្សព្វផ្សាយរូបភាពរបស់នាងនៅលើទំព័រហ្វេសប៊ុកប៉ុណ្ណោះ ។ [6]

[6] https://www.khmertimeskh.com/50746757/woman-sought-for-propositioning-clients-on-social-media/

# សេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ

នៅក្នុងខែមិថុនា ឆ្នាំ២០២០ ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើសេចក្តីព្រាងច្បាប់មួយស្តីពីសណ្តាប់ធ្នាប់សាធារណៈ [7] ប៉ុន្តែអង្គការសង្គមស៊ីវិល ទើបតែទទួលបានសេចក្តីព្រាងច្បាប់នេះនៅក្នុងខែកក្កដា និងខែសីហា ឆ្នាំ២០២០ តែប៉ុណ្ណោះ។ ទោះបីជាគណៈកម្មាធិការនៃអង្គការសហប្រជាជាតិ ទទួលបន្ទុកលើអនុសញ្ញា ស៊ី ដ បានផ្តល់អនុសាសន៍នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៩ ថារដ្ឋាភិបាលកម្ពុជាគួរធ្វើការវិភាគយេនឌ័រទូលំទូលាយគ្រប់ជ្រុងជ្រោយមួយ នៅក្នុងការធ្វើសេចក្តីព្រាងច្បាប់ថ្មីណាមួយក៏ដោយ [8] ក៏មិនមានការចង្អុលបង្ហាញថាក្រសួងបានធ្វើការវិភាគបែបនេះ ឬធ្វើការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល ដែលបានធ្វើការងារដោយផ្ទាល់ជាមួយក្រុមគោលដៅនៅក្នុង សហគមន៍ ដែលអាចនឹងទទួលរងផលប៉ះពាល់ខ្លាំងដោយសារច្បាប់នេះ ដោយរួមបញ្ចូលទាំងក្រុមស្រ្តី ក្រុមជនមានពិការភាព និងក្រុមអ្នកប្រកបរបរក្នុង វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផងដែរ។

មានការជំទាស់តវ៉ាជាសាធារណៈច្រើនទៅលើសេចក្តីព្រាងច្បាប់នេះ។ ក្នុងខែសីហាឆ្នាំ២០២០ តាន់ ម៉ូលីកា និស្សិតកម្ពុជាម្នាក់បានចាប់ផ្តើមធ្វើញត្តិតាមប្រព័ន្ធអនឡាញ [9] ដោយប្រមូលបាននូវហត្ថលេខាជាច្រើន នៅក្នុងការជំទាស់តវ៉ាទៅលើសេចក្តីព្រាងច្បាប់ដែលរំលោភបំពានទៅលើសិទ្ធិរបស់ស្រ្តីនិងក្មេងស្រីក្នុងការសម្តែងមតិ និងជម្រើសនៃការស្លៀកពាក់របស់ពួកគេ។ រហូតមកដល់ចុងខែតុលាឆ្នាំ២០២០ មានមនុស្សប្រមាណ ២១,000នាក់ បានចុះហត្ថលេខាគាំទ្រញត្តិនោះ។ ក្នុងខែសីហាឆ្នាំ២០២០ អង្គការសង្គមស៊ីវិលបានចេញសេចក្តីថ្លែងការណ៍រួមចំនួនពីរ ទាមទារឲ្យរដ្ឋាភិបាលទម្លាក់ ចោលសេចក្តីព្រាងច្បាប់នេះទាំងស្រុង ដោយសារតែវាបានរំលោភបំពានទៅលើសិទ្ធិមនុស្ស។ សេចក្តីថ្លែងការណ៍មួយ បានផ្តោតទៅលើការរំលោភបំពានសិទ្ធិស្រ្តី និងទទួលបានការគាំទ្រពីសំណាក់ក្រុមអង្គការសង្គមស៊ីវិលចំនួន៨៤ ដោយរួមបញ្ចូលទាំង អង្គការមិនមែនរដ្ឋាភិបាល សហជីព និងក្រុមអង្គការមហាជននានានៅតាមមូលដ្ឋានដែរ។

សេចក្តីថ្លែងការណ៍រួមបានកត់សម្គាល់ថា សេចក្តីព្រាងច្បាប់នេះ មានបទប្បញ្ញត្តិជាច្រើនដែលកំណត់ទោសជាបទល្មើសព្រហ្មទណ្ឌ ទៅលើសកម្មភាពស្របច្បាប់ប្រចាំថ្ងៃរបស់មនុស្សជាច្រើន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលជាការរំលោភបំពានទៅលើ សិទ្ធិសេរីភាពក្នុងការសម្តែងមតិ សមាគម ការជួបជុំ និងសិទ្ធិមនុស្សផ្សេងៗទៀតដែលទទួលបានការការពារ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ សន្ធិសញ្ញាដែលបានផ្តល់សច្ចាប័ន និងការប្តេជ្ញាចិត្តនានាដែលធ្វើឡើងនៅក្នុងដំណើរការពិនិត្យឡើងវិញជាសាកលតាមការកំណត់ (UPR) និងនៅក្នុងគោលនយោបាយថ្នាក់ជាតិផ្សេងៗទៀត។ ជាងនេះទៅទៀត រដ្ឋាភិបាលមិនត្រឹមតែមិនបានលើកកម្ពស់នូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការសម្រេចឱ្យបាននូវសមភាពយេនឌ័រនោះទេ ហើយថែមទាំងដាក់ទោសព្រហ្មទណ្ឌទៅលើទង្វើរបស់ស្រ្តីដែលបដិសេធមិនព្រមអនុវត្តតាមស្តង់ដារនៃការស្លៀកពាក់ និងស្តង់ដារ ក្រមសីលធម៌ដែលកំណត់ដោយរដ្ឋដែលមានចរិកអភិរក្សនិយមនិងអយុត្តិធម៌សម្រាប់ស្រ្តី និងការដាក់ទោសទណ្ឌទៅលើអ្នកដែលធ្វើសកម្មភាពប្រកបរបរចិញ្ចឹមជីវិតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រចាំថ្ងៃធម្មតាៗ ដូចជាការលក់ដូរនៅតាមដងផ្លូវ ដែលត្រូវបានគេចាត់ទុកថាជាការដែលសង្គមមិនចង់បានឬធ្វើឲ្យបាត់បង់សោភ័ណ្ឌភាព។

[7] https://www.voacambodia.com/a/draft-public-order-law-looks-to-control-cambodians-behavior-and-activities/5502253.html
[8] CEDAW Concluding Observations 2019, Paragraph 9(b) states that RGC should “Systematically undertake gender impact assessments when adopting or revising laws, and ensure that legislative changes help to promote and protect the rights of women.”
[9] https://www.change.org/p/teenagers-cambodia-stop-oppressing-women-s-rights-through-law

ស្រដៀងគ្នានេះដែរ រដ្ឋាភិបាលកម្ពុជាមិនអាចធ្វើការកាត់បន្ថយអត្រាខ្ពស់នៃអំពើហិង្សាផ្លូវភេទនិងការរុកកួនផ្លូវភេទនៅក្នុងប្រទេសកម្ពុជាបានទេ បើសិនជារដ្ឋាភិបាលមិនធ្វើការថ្កោលទោសចំពោះការស្តីបន្ទោស ជនរងគ្រោះ និងផ្តន្ទាទោសជនប្រព្រឹត្តិរាល់ទម្រង់នៃអំពើហិង្សាផ្លូវភេទ។ វាមានភាពចាំបាច់ណាស់ក្នុងការលើកកម្ពស់ស្ត្រី ទាក់ទងនិងបូរណភាពរាងកាយនិងសិទ្ធិក្នុងការទទួលបានស្វ័យភាពផ្លូវភេទ។

ការអនុម័តច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈនេះ នឹងប្រឆាំងទៅលើមាត្រា៥ នៃអនុសញ្ញា ស៊ី ដ ដែលតម្រូវឱ្យរដ្ឋាភិបាលចាត់រាល់វិធានការសមស្របទាំងឡាយដើម្បី “កែប្រែផ្នត់គំនិតសង្គម និងវប្បធម៌របស់បុរសនិងស្ត្រី ដើម្បីសម្រេចបាននូវការលុបបំបាត់សេចក្តីលម្អៀងនិងទម្លាប់ និងការអនុវត្តជាទម្លាប់ផ្សេងៗទៀត ផ្អែកលើគំនិតស្តីពីភាពទាបជាង ឬខ្ពស់ជាងរបស់ភេទណាមួយ ឬលើតួនាទីដែលជាទម្លាប់សម្រាប់បុរសនិងស្ត្រី”។ ជាងនេះទៀត សេចក្តីសង្កេតសន្និដ្ឋានឆ្នាំ២០១៩ របស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួល បន្ទុកលើអនុញ្ញា ស៊ី ដ ( គណៈកម្មាធិការស៊ី ដ ) បានផ្តល់អនុសាសន៍ថា រដ្ឋាភិបាលកម្ពុជា “គួរធ្វើការប៉ាន់ប្រមាណជាលក្ខណៈប្រព័ន្ធទៅលើផលប៉ះពាល់នៃវិធានការដែលបានអនុម័តនៅក្នុងការប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រទៅលើស្ត្រី និងក្មេងស្រីព្រមទាំងបន្តរុករកស្រាវជ្រាវ និងអនុម័តនូវវិធីសាស្ត្រថ្មីៗ ដើម្បីដោះស្រាយ ឫសគល់នៃអំពើហិង្សាទាំងនេះ”។ បន្ថែមលើនេះទៀត នៅក្នុងសេចក្តីសង្កេតសន្និដ្ឋាននោះ ត្រង់កថាខណ្ឌ៩(ខ) គណៈកម្មាធិការស៊ី ដ បានផ្តល់អនុសាសន៍ថា រដ្ឋាភិបាលកម្ពុជា “គួរធ្វើការប៉ាន់ប្រមាណផលប៉ះពាល់យេនឌ័រជាលក្ខណៈប្រព័ន្ធ នៅពេលធ្វើការអនុម័ត ឬវិសោធនកម្មច្បាប់ ព្រមទាំងធានាថា ការផ្លាស់ប្តូរនានានៅក្នុងច្បាប់ ជួយលើកកម្ពស់និងការពារសិទ្ធិស្ត្រី”។ ភាសាដែលបានប្រើប្រាស់នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈនាពេលបច្ចុប្បន្ននេះ ចង្អុលបង្ហាញថារដ្ឋាភិបាលកម្ពុជារហូតមកដល់ពេលនេះ បានខកខាន និងមិនបានធ្វើការប៉ាន់ប្រមាណណាមួយទៅលើផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងទៅលើស្ត្រី និងផ្តល់ផលប៉ះពាល់ដែលអាចជាការបន្ទាបបន្ថោកនិងការបង្កគ្រោះថ្នាក់ទៅដល់សិទ្ធិស្ត្រី ដែលផ្ទុយពីកាតព្វកិច្ចរបស់ប្រទេសកម្ពុជានៅក្រោមអនុសញ្ញា ស៊ី ដ ។

# អំពើហិង្សាផ្អែកលើយេនឌ័រ

អំពើហិង្សាលើស្ត្រី ដោយរួមបញ្ចូលទាំងអំពើហិង្សាបង្កដោយដៃគូស្និទ្ធស្នាល បន្តនៅជាក្តីបារម្ភដ៏ធ្ងន់ធ្ងរមួយនៅក្នុងប្រទេសកម្ពុជា។ ក្នុងរយៈពេលពេញមួយឆ្នាំនៃឆ្នាំ២០២០នេះ មានរបាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយជាច្រើនអំពីបុរសដែលបានសម្លាប់ដៃគូរបស់ខ្លួន [10] ដោយសារនៅកម្ពុជាមិនមានការប្រកាសបិទប្រទេស ទាំងស្រុងដែលធ្វើឱ្យមានករណីអំពើហិង្សាក្នុងគ្រួសារកើនឡើងខ្លាំងដូចនៅប្រទេសដទៃ ក៏ប៉ុន្តែសម្ពាធសេដ្ឋកិច្ច គ្រួសារដែលបណ្តាលមកពីវិបត្តិកូវីដ-១៩នេះ អាចជាហានិភ័យនាំឱ្យមានអំពើហិង្សាក្នុងគ្រួសារផងដែរ។ ជាក់ស្តែង ចំនួនពលករចំណាកស្រុកជាស្ត្រីដែលបានវិលត្រឡប់មកផ្ទះវិញមានការកើនឡើង ហើយក៏មិនមានឱកាសស្វែងរកប្រាក់ចំណូលនៅក្នុងប្រទេសកម្ពុជាដែរ។ ស្ត្រីក៏បានបាត់បង់ប្រាក់ចំណូលតាមរយៈការបង្ខំចិត្ត ចាកចេញពីការងារដែលមានប្រាក់កម្រៃនៅខាងក្រៅផ្ទះ មកធ្វើការងារថែទាំដែលគ្មានប្រាក់កម្រៃ និង មើលការខុសត្រូវទៅលើកូនៗដែលមិនអាចទៅសាលារៀនបាន នៅក្នុងឆ្នាំ២០២០នេះ។

[10] https://www.phnompenhpost.com/national/wife-set-fire-over-jealousy

វិធានការវិជ្ជមានមួយដែលបានចាត់ឡើងដោយប្រទេសកម្ពុជា នៅក្នុងកំឡុងពេលនៃការអនុវត្តក្រម ប្រតិបត្តិសារព័ត៌មានក្នុងការរាយការណ៍អំពើហិង្សាលើស្ត្រី (ប្រកាសរួមរវាងក្រសួងកិច្ចការនារី និងក្រសួងព័ត៌មាន ឆ្នាំ២០១៧)។ ការបណ្តុះបណ្តាលសម្រាប់អ្នកសារព័ត៌មានត្រូវបានរៀបចំឡើងដោយក្រសួងកិច្ចការនារី និងក្រសួងព័ត៌មាន នៅចុងឆ្នាំ២០២០ [11] ។ ក្រសួងទាំងពីរក៏បានបង្កើតក្រុមការងារ ក្នុងការតាមដាននិងការអនុវត្តក្រមប្រតិបត្តិនេះផងដែរ។

វិធីសាស្ត្រក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវបានគេនិយមប្រើប្រាស់ច្រើននៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងការឆ្លើយតបទៅនឹងបញ្ហាអំពើហិង្សាក្នុងគ្រួសារ។ គណៈកម្មាធិការនៃអនុសញ្ញា ស៊ី ដ បានបញ្ជាក់យ៉ាងច្បាស់អំពីក្តីបារម្ភរបស់ខ្លួន នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានឆ្នាំ២០១៣ និងឆ្នាំ២០១៩ បន្ទាប់ពីមានការពិនិត្យឡើងវិញទៅលើការអនុវត្តអនុសញ្ញា ស៊ីដ របស់ប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០១៣ គណៈកម្មាធិការបានស្នើឱ្យមានការបណ្តុះបណ្តាលអំពីការអនុវត្តច្បាប់ប្រឆាំងអំពើហិង្សាឱ្យបានតឹងរឹង ដើម្បីឲ្យ “បញ្ឈប់ការដាក់បញ្ចូលករណីអំពើហិង្សាផ្អែកលើយេនឌ័រ នៅក្នុងវិធីសាស្ត្រសម្រុះសម្រួលជាលក្ខណៈប្រព័ន្ធក្រៅប្រព័ន្ធតុលាការ និងបញ្ជូនសំណុំរឿងទៅកាត់ទោសនៅក្នុងប្រព័ន្ធតុលាការ [12]”។ ក្នុងឆ្នាំ២០១៩ គណៈកម្មាធិការនេះ ក៏បានបញ្ជាក់បន្ថែមទៀត អំពីក្តីបារម្ភថា “ការផ្សះផ្សាក្រៅប្រព័ន្ធតុលាការដោយសមាជិកសហគមន៍ ដែលមិនបានទទួលការបណ្តុះ-បណ្តាលជាផ្លូវការណាមួយនោះនិងនៅតែបន្តប្រើប្រាស់ជា មធ្យោបាយចម្បងក្នុងការដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារ [13]”។ ទាក់ទងនឹងក្តីបារម្ភរបស់គណៈកម្មាធិការនេះ ក្នុងឆ្នាំ២០២០ អង្គការនារីដើម្បីសន្តិភាព និងអង្គការក្លាហាន បានធ្វើការស្រាវជ្រាវមួយស្តីពីការប្រើប្រាស់ការអនុវត្តន៍ដំណោះស្រាយវិវាទនៅមូលដ្ឋាន ក្នុងករណីអំពីហិង្សាលើដៃគូស្និទ្ធស្នាល ក្នុងប្រទេសកម្ពុជា ហើយបានរកឃើញនូវការប្រើប្រាស់ដោយមិនត្រឹមត្រូវទៅលើការអនុវត្តទាំងនេះយ៉ាងខ្លាំង [14] ។ របាយ-ការណ៍ស្រាវជ្រាវដែលបានបោះពុម្ពផ្សាយនេះ បានកត់សម្គាល់ថា ខណៈដែលច្បាប់នៃប្រទេសកម្ពុជាអនុញ្ញាតឲ្យមាន “ការសម្រុះសម្រួល” នៅក្នុងកាលៈទេសៈមួយចំនួននោះ លទ្ធផលដែលរកឃើញបានបង្ហាញថា អ្វីដែលកើតឡើងច្រើនបំផុតនៅក្នុងការអនុវត្តជាក់ស្តែងនោះ គឺជា “ការផ្សះផ្សា” ។ ភាពខុសប្លែកគ្នាដ៏ធំនោះគឺថា ការផ្សះផ្សាត្រូវបានធ្វើឡើងដោយមានគោលបំណងច្បាស់លាស់នៅក្នុងការបញ្ចុះបញ្ចូលជនរងគ្រោះពីអំពើហិង្សាលើដៃគូស្និទ្ធស្នាលឲ្យបន្តរស់ជាមួយអ្នកប្រព្រឹត្តអំពើហិង្សា។ ការស្រាវជ្រាវនោះក៏បានបង្ហាញដែរថា ការដោះស្រាយវិវាទតាមបែបប្រពៃណីនាពេលបច្ចុប្បន្ននេះ មិនបានឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ឬមិនបានចាត់ទុក តម្រូវការរបស់ជនរងគ្រោះជាចំណុចចម្បងនោះទេ ហើយត្រូវបានយកមកប្រើប្រាស់នៅក្នុងកាលៈទេសៈមួយដែលមិនសមស្របទាល់តែសោះ (ឧទាហរណ៍ វិធីសាស្ត្រនេះត្រូវបានយកមកប្រើក្រោយពេលមានបទល្មើសមជ្ឈិម ឬសូម្បីក្រោយពេលដែលមានបទល្មើសឧក្រិដ្ឋកើតឡើង) ហើយធ្វើឡើងដោយតួអង្គមិនសមស្រប (ឧទាហរណ៍ មន្ត្រីនគរបាល) ហើយជារឿយៗ ដោយគ្មានការយល់ព្រមដោយពេញលេញនិងមានព័ត៌មានគ្រប់គ្រាន់ពីភាគីពាក់ព័ន្ធនោះទេ។

ឧទាហរណ៍ដែលគួរឲ្យកត់សម្គាល់មួយនោះ គឺការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនមានភាពត្រឹមត្រូវ ក្នុងឆ្នាំ២០២០ គឺការអនុវត្តរបស់លោកប្រធានក្រុមប្រឹក្សាភិបាល

[11] Training events were covered by media: https://www.information.gov.kh/articles/27335 and https://kohsantepheapdaily.com.kh/article/1218827.html
[12] CEDAW Committee ‘Concluding Observations on the Fourth and Fifth Periodic Report on Cambodia’, (2013) CEDAW/C/KHM/CO/4-5, para 21(a).
[13] CEDAW Committee ‘Concluding Observations on the Sixth Periodic Report on Cambodia’, (2019) CEDAW/C/KHM/CO/6, para 24(b).
[14] Women Peace Makers et al (2020): Preserving Harmony or Preventing Justice? online: <https://bit.ly/37gwsrL>.

នៃគណៈអភិបាលខេត្តពោធិសាត់ នៅក្នុងករណីផ្សះផ្សាប្តីប្រពន្ធមួយគូនៅក្នុងវេទិកាសាធារណៈ។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០ ទូរទស្សន៍ជាតិប្រចាំខេត្តពោធិសាត់បានចាក់ផ្សាយវីដេអូអំពីសកម្មភាពនៃការផ្សះផ្សានេះ [15]។ ស្ត្រីម្នាក់បានស្នើសុំលែងលះ ដោយសារតែប្តីរបស់គាត់បានវាយដំមកលើគាត់ម្តងហើយម្តងទៀត។ ម្តាយរបស់ ស្ត្រីនោះក៏បានអះអាងដែរថា អំពើហិង្សានោះមានសភាពធ្ងន់ធ្ងរពេក ហើយពួកគេគួរតែលែងលះ។ បុរសជាប្តី បានសុំអភ័យទោស និងនិយាយថា ខ្លួនមិនចង់លែងលះទេ។ លោកប្រធានក្រុមប្រឹក្សាភិបាលនៃគណៈអភិបាលខេត្តពោធិសាត់បានអប់រំទូន្មានប្តីប្រពន្ធមួយគូនេះម្តងហើយម្តងទៀត អំពីភាពចាំបាច់ត្រូវធ្វើក្នុងជីវិតអាពាហ៍ពិពាហ៍ និងបានទទូចឲ្យប្តីប្រពន្ធនេះផ្សះផ្សាគ្នាវិញ។ ស្ត្រីនោះបានសុំម្តងហើយម្តងទៀតឲ្យមានការបែកគ្នាពីប្តីរបស់នាង ប៉ុន្តែលោកអភិបាលខេត្តបានបដិសេធការស្នើសុំរបស់នាង។ វីដេអូនេះ មានការចូលមើលរហូតដល់ ៧៥០.០០០ ដង ដោយមានមតិឆ្លើយតបវិជ្ជមានច្រើនជាងអវិជ្ជមានរហូតដល់ដប់ដង។ ឧទាហរណ៍បែបនេះ ពីមន្ត្រីអាជ្ញាធរជាន់ខ្ពស់បន្តជម្រុញឲ្យមានការអនុវត្តវិធីសាស្ត្របែបផ្សះផ្សា ដែលផ្ទុយទៅនឹងច្បាប់កម្ពុជា និងអនុសាសន៍របស់គណៈកម្មាធិការនៃអនុសញ្ញា ស៊ី ដ។




មានក្តីបារម្ភជាក់លាក់មួយ ទាក់ទងនឹងចំនួនករណីអំពើហិង្សាទៅលើកុមារដែលមានចំនួនខ្ពស់នៅក្នុងប្រទេសកម្ពុជា ព្រមទាំងសក្តានុពលនៃការបង្ករការបំពានដែលមានការកើនឡើងទៅលើកុមារ ដែលមិនត្រូវបានធ្វើការតាមដាននិងរកឃើញដោយសារតែការបិទសាលារៀន។ ជាឧទាហរណ៍ អង្គការ លីកាដូ បានរាយការណ៍ថា ៣១% នៃករណីរំលោភសេពសន្ថវៈនៅពេលថ្មីៗនេះ មានការពាក់ព័ន្ធជាមួយនឹងជនល្មើសដែលជាសាច់ញាតិរបស់ជនរងគ្រោះ [16]។ ករណីទាំងនេះភាគច្រើនពាក់ព័ន្ធជនរងគ្រោះជាកុមារ និងមិនរាប់បញ្ចូលករណីនៃអំពើហិង្សាបង្កដោយដៃគូស្និទ្ធស្នាលទេ។ ចំនួនទាំងនេះមានភាពស៊ីសង្វាក់ជាមួយនឹងស្ថិតិរបស់រដ្ឋាភិបាលដែលបង្ហាញថា ជនរងគ្រោះភាគច្រើននៃអំពើហិង្សាផ្លូវភេទស្គាល់ជនប្រព្រឹត្ត [17] ។ តាមរយៈការដែលកុមារមិនអាចទៅសាលារៀនក្នុងរយៈពេល

[15] https://www.youtube.com/watch?v=Cx-c-u9wS4s accessed on 27 Feb 2021.
[16] LICADHO, "Broken Silence: Rape by Relatives and Barriers to Justice in Cambodia," December 2020
[17] UNICEF, Findings from Cambodia Violence Against Children Survey 2013, p. 72. Most perpetrators of sexual violence against children are partners, family, friends, or neighbors, with neighbors comprising the largest percentage (28-37%) for both boys and girls. November 2015 National Survey on Women's Health and Life Experiences in Cambodia (sponsored by WHO and RGC), p 48, 58, 60-61. 4% of survey respondents experienced sexual violence after age 15 by a non-partner, while 10.2% of ever-partnered women had experienced sexual violence by an intimate partner. These numbers do not include sexual harassment.

ជាច្រើនខែនៅក្នុង១ឆ្នាំនោះ ជនបង្កមានឱកាសកាន់តែច្រើនឡើងនៅក្នុងការប្រព្រឹត្តអំពើហិង្សាទៅលើកុមារ ខណៈដែលភាគីទីបី ដូចជាគ្រូបង្រៀន មានឱកាសតិចតួចណាស់នៅក្នុងការផ្តល់អន្តរាគមន៍ដើម្បីជួយដល់កុមារ។

ក្តីបារម្ភមួយទៀត គឺកង្វះច្បាប់ និងគោលនយោបាយគ្រប់ជ្រុងជ្រោយ ក្នុងការដោះស្រាយនៅកម្រិតខ្ពស់នៃការបៀតបៀន និងអំពើហិង្សាផ្អែកលើយេនឌ័រផ្សេងទៀតនៅកន្លែងធ្វើការងារ។ ទោះជាមានភាពវិជ្ជមាន ដែលរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ជាសាធារណៈថារដ្ឋាភិបាលកម្ពុជាប្តេជ្ញាក្នុងការលុបបំបាត់អំពើហិង្សានៅកន្លែងការងារ និងថាប្រទេសកម្ពុជាបានបោះ-ឆ្នោតគាំទ្រការអនុម័តអនុសញ្ញា ILO C190 [18] ក៏ដោយ ក៏ប្រទេសកម្ពុជាមិនទាន់បានផ្តល់សច្ចាប័នទៅលើអនុសញ្ញានេះនៅឡើយ។ ជាងនេះទៀត កម្ពុជាមិនទាន់បានដាក់ចេញនូវវិធានការហ្មត់ចត់ណាមួយ ដើម្បីដោះស្រាយបញ្ហានេះជាប្រព័ន្ធនៅឡើយទេ។ អនុសញ្ញា ILO C190 ចែងអំពីក្របខណ្ឌនិងអនុសាសន៍ច្បាស់លាស់ សម្រាប់ដោះស្រាយអំពើហិង្សានិងការបៀតបៀនផ្អែកលើយេនឌ័រក្នុងពិភពការងារ ព្រមទាំងពង្រីកវិសាលភាពនៃការការពារដល់កម្មករនិយោជិកទាំងអស់។

ក្តីបារម្ភមួយទៀតដែលបានបង្ហាញអោយឃើញកាន់តែច្បាស់នៅក្នុងឆ្នាំ២០២០នោះ គឺការណ៍ដែលរដ្ឋាភិបាលបដិសេធមិនធ្វើការផ្តន្ទាទោសទៅលើករណីមួយចំនួន នៃអំពើហិង្សាផ្លូវភេទដែលបង្កឡើងដោយអាជ្ញាធរ។ មន្ត្រីប៉ូលីសជាន់ខ្ពស់ម្នាក់ត្រូវបានគេរកឃើញថា បានប្រព្រឹត្តបទល្មើសប្រទូសកេរ្តិ៍ខ្មាស់ទៅលើមន្ត្រីនគបាលជាស្ត្រីចំនួន ៤នាក់ ដែលនេះគឺជាទម្រង់នៃការរំលោភអំណាចដ៏ធ្ងន់ធ្ងរមួយ។ មានការបើកការស៊ើបអង្កេតទៅលើស្នងការនគបាលខេត្តកំពង់ធំ អ៊ុក កុសល ដែលជាឧត្តមសេនីយផ្កាយ ២មួយរូបនោះ បន្ទាប់ពីស្ត្រី៤រូបបានដាក់ពាក្យបណ្តឹងជាផ្លូវការ ប៉ុន្តែលោកស្នងការរូបនោះមិនត្រូវបានដកចេញពីតួនាទីឡើយ រហូតដល់មានការទាមទារជាសាធារណៈដ៏ខ្លាំងក្លាមួយបានធ្វើឡើងទើបមានការទម្លាក់តំណែងបុគ្គលរូបនោះ ប៉ុន្តែមិនមានការលុបឈ្មោះគាត់ចេញពីបញ្ជីក្រប-ខណ្ឌការងារនៅក្នុងជួររដ្ឋាភិបាលទេ មិនតែប៉ុណ្ណោះគាត់ក៏មិនប្រឈមនឹងការផ្តន្ទាទោសនៅក្នុងប្រព័ន្ធតុលាការដែរ ពីព្រោះអាជ្ញាធរបានដាក់ការទទួលខុសត្រូវនេះទៅលើជនរងគ្រោះក្នុងការដឹកនាំបន្តទៅលើករណីព្រហ្មទណ្ឌមួយនេះ [19]។ នេះគឺជាការខកខានឱកាសមួយសម្រាប់រដ្ឋាភិបាល ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនស្របទៅនឹងអនុសញ្ញា ស៊ី ដ ក្នុងការផ្តល់ការការពារដល់ជនរងគ្រោះ ព្រមទាំងធានាថា ជនរងគ្រោះនឹងទទួលបានយុត្តិធម៌ និងការដោះស្រាយលើគ្រោះថ្នាក់ទាំងឡាយណាដែលបានបង្កឡើងនៅក្នុងសង្គម និងស្ថាប័នរដ្ឋាភិបាលទាំងមូល តាមរយៈប្រភេទនៃអំពើហិង្សានៅក្នុងស្ថាប័ននេះ។

[18] https://www.care.org.au/wp-content/uploads/2020/01/TheBusinessofWomenAtWork_finalreport.pdf
[19] https://www.straitstimes.com/asia/se-asia/cambodia-police-chief-sacked-over-sexual-misconduct-in-landmark-case

# ការរឹតត្បិតទៅលើសេរីភាពបញ្ចេញមតិ ការជួបជុំ និងសារព័ត៌មាន

រដ្ឋាភិបាលកំពុងតែធ្វើការតាមដានច្រើនឡើងៗទៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម និងការប្រមូលផ្តុំ ដើម្បីយកមកកាត់ទោស ឬបានឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សជាស្ត្រី។ នេះគឺជាភស្តុតាងជាក់លាក់មួយអំពីបុគ្គលដែលបានសម្តែងមតិរបស់ខ្លួន ហើយត្រូវបានយល់ថាជាការរិះគន់ទៅលើរដ្ឋាភិបាល ទៅលើប្រធានបទបរិស្ថាននិងនយោបាយ។

អ្នកសារព័ត៌មានជាស្ត្រី និងអ្នកតស៊ូមតិជាស្ត្រីដែលកំពុងស្វែងរកការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា បានទទួលរងនូវការចាប់ខ្លួននិង/ឬការបៀតបៀនផ្សេងៗ [20] ។ ក្នុងរយៈពេលពេញមួយឆ្នាំនៃឆ្នាំ២០២០នេះ ការបំផ្លាញជម្រកសត្វព្រៃ ព្រៃឈើ និងផ្លូវទឹក [21] រួមចំណែកអវិជ្ជមានទៅដល់ការប្រែប្រួលអាកាសធាតុ។ សមាជិកអង្គការសង្គមស៊ីវិលដែលធ្វើការចងក្រងឯកសារអំពីការបំផ្លិចបំផ្លាញ និងបោះពុម្ពផ្សាយភស្តុតាងនៅតាមប្រព័ន្ធអ៊ីនធឺណេត បានទទួលរងការចាប់ឃុំខ្លួនជាដើម។ សកម្មជនបរិស្ថានជាស្ត្រីចំនួន២នាក់ ភួង កែវរស្មី និងឡុង គន្ធា ត្រូវបានឃុំខ្លួននៅក្នុងខែកញ្ញា ឆ្នាំ២០២០ រួមជាមួយនិងសហការីជាបុរសរបស់ពួកគាត់គឺ ធន់ រដ្ឋា ពីបទចែករំលែកព័ត៌មាននៅលើប្រព័ន្ធផ្សព្វផ្សាយហ្វេសប៊ុក អំពីការរៀបចំការដង្ហែក្បួនរបស់ស្ត្រីម្នាក់ ដែលត្រូវបានរៀបចំផែនការឡើងដោយ ឡុង គន្ធា ដើម្បីតវ៉ាប្រឆាំងទៅនឹងការបំផ្លិចបំផ្លាញយ៉ាងខ្លាំងទៅលើបឹងធម្មជាតិមួយ ក្នុងចំណោម បឹងធម្មជាតិតិចតួចដែលនៅសេសសល់នៅក្នុងទីក្រុងភ្នំពេញតាមរយៈការចាក់ដីលុបបឹង ដើម្បីធ្វើការសាងសង់ផ្សេងៗនោះ [22]។ ការបំផ្លាញបឹងធម្មជាតិ បានបង្កឱ្យមានការផ្លាស់ប្តូរការតាំងទីលំនៅដោយបង្ខំ នឹងបានធ្វើឱ្យទឹកជំនន់នៅក្នុងរាជធានីកាន់តែមានភាពអាក្រក់ឡើង។

សូម្បីតែសកម្មភាពជាប្រចាំក្នុងការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន ដូចជាពិធីបំបួសព្រៃប្រចាំឆ្នាំនៅក្នុងតំបន់ព្រៃឡង់ ក៏ត្រូវបានអាជ្ញាធរហាមឃាត់ដែរ [23]។ សមាជិកសហគមន៍ត្រូវបានរាំងមិនឱ្យចូលទៅក្នុងព្រៃ ហើយត្រូវបានចាប់ខ្លួនពីបទប៉ុនប៉ងចូលទៅក្នុងព្រៃនេះ ទោះបីជាមិនមានច្បាប់ណាមួយ ចែងប្រឆាំងនឹងទង្វើនេះក៏ដោយ។

ចាប់ពីខែសីហាឆ្នាំ២០២០មក បន្ទាប់ពីមានការចាប់ខ្លួនថ្នាក់ដឹកនាំសហជីព លោក រ៉ុង ឈុន ស្ត្រីអ្នកការពារសិទ្ធិមនុស្សកាន់តែច្រើនឡើងត្រូវបានគេចាប់ខ្លួន និងឃុំឃាំងនៅក្នុងពន្ធនាគារ។ សកម្មជនយុវជនជាស្ត្រីចំនួន ៣នាក់គឺ សរ កន្និកា, ឈឿន ដារ៉ាវី និង អេង ម៉ាល័យ ត្រូវបានចាប់ខ្លួន បន្ទាប់ពីការអំពាវនាវដោយសន្តិវិធីឱ្យមានការដោះលែង លោក រ៉ុង ឈុន និងសកម្មជនដទៃទៀត [24] ។

[20] https://www.licadho-cambodia.org/articles/20200922/169/index.html
[21] https://www.npr.org/2020/02/27/808807512/houses-on-the-river-will-fall-cambodia-s-sand-mining-threatens-vital-mekong
[22] https://vodenglish.news/three-mother-nature-activists-arrested-as-one-woman-march-shut-down-mid-production/
[23] https://www.voacambodia.com/a/civil-society-calls-blocking-of-forest-blessing-ceremony-indefensible/5302780.html
[24] https://www.licadho-cambodia.org/articles/20200922/169/index.html

សកម្មជនម្នាក់ៗដែលត្រូវបានចាប់ខ្លួនដូចដែលបានរៀបរាប់ខាងលើនេះ ត្រូវបានចោទប្រកាន់ពីបទ "ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ឬការបង្កឱ្យមានចលាចលនៅក្នុងសង្គម" តាមមាត្រា៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ហើយបច្ចុប្បន្នបន្តជាប់ក្នុងការឃុំខ្លួនបណ្ដោះអាសន្ន [25]។

ជាងនេះទៅទៀត ស្ត្រីអ្នកការពារសិទ្ធិមនុស្សជាច្រើន ដោយរួមបញ្ចូលទាំងប្រពន្ធ និងសាច់ញាតិរបស់អតីតសមាជិកគណបក្សជំទាស់ដែលត្រូវបានរំលាយទៅហើយ ហើយកំពុងជាប់ឃុំឃាំងនោះ ក៏ត្រូវបានបដិសេធសិទ្ធិមិនឱ្យធ្វើការតវ៉ាដោយសន្តិវិធី ចំពោះការឃុំខ្លួនបន្តបន្ទាប់ទៅលើអតីតសមាជិកគណបក្សជំទាស់ ក្នុងការសម្ដែងមតិយោបល់បែបរិះគន់ដល់រដ្ឋាភិបាល [26] ។ ការតវ៉ាបានធ្វើឡើងរៀងរាល់ថ្ងៃសុក្រដែលរៀបចំឡើង ដោយប្រពន្ធរបស់អតីតសកម្មជនកំពុងជាប់ក្នុងពន្ធនាគារ ដើម្បីទាមទារឱ្យមានការដោះលែងសាច់ញាតិរបស់ពួកគេ ប៉ុន្តែការជួបជុំរបស់ពួកគេត្រូវបានមន្ត្រីនគបាលធ្វើការបំបែកនិងគំរាមចាប់ខ្លួន ហើយពេលខ្លះមានប្រើប្រាស់កម្លាំងដើម្បីបំបែកពួកគេចេញទៀតផង [27]។

# ការទទួលបានការអប់រំសម្រាប់ក្មេងស្រី

នៅក្នុងខែសីហាឆ្នាំ២០២០ មានកិច្ចសហការជាមួយអង្គការ JICA រដ្ឋាភិបាលកម្ពុជាបានបញ្ចេញស្ថិតិយេនឌ័រសម្រាប់ខេត្តកំពង់ធំ ហើយទិន្នន័យពីរបាយការណ៍នេះ បង្ហាញថាក្នុងខេត្តកំពង់ធំ ស្ត្រីមានការចូលរៀនច្រើននៅក្នុងសាលាបឋមសិក្សានៅស្ទើរតែគ្រប់ស្រុក ប៉ុន្តែនៅក្នុងកម្រិតអនុវិទ្យាល័យនិងវិទ្យាល័យ នៅតាម ស្រុកទាំងអស់បានបង្ហាញអំពីការចុះឈ្មោះចូលរៀនរបស់ក្មេងប្រុសមានកម្រិតខ្ពស់ជាងខ្លាំង។ ប្រហែលជា៣៥% នៃសិស្សថ្នាក់មធ្យមសិក្សាជាសិស្សស្រី ខណៈដែល ៦៥% ជាសិស្សប្រុស [28]។

# ស្ត្រីនិងក្មេងស្រីដែលកំពុងជាប់ឃុំ

ទោះបីជាអង្គការសង្គមស៊ីវិលទទួលស្គាល់និងកោតសសើរ ចំពោះការជូនដំណឹងមួយដែលធ្វើឡើងនៅខែឧសភាឆ្នាំ២០២០ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តម កើត រិទ្ធ អំពីយុទ្ធនាការនៅក្នុងការកាត់បន្ថយសំណុំរឿងដែលនៅសេសសល់នៅក្នុងប្រព័ន្ធច្បាប់ និងកាត់បន្ថយការកកស្ទះនៅក្នុងពន្ធនាគារ ព្រមទាំងទទួលជោគជ័យក្នុងការកាត់បន្ថយករណីកកស្ទះក៏ដោយ ក៏យើងមានការកត់សម្គាល់ដែរថា វាមិនបានទទួលលទ្ធផលតាមការរំពឹងទុកក្នុងការកាត់បន្ថយភាពកកស្ទះនៅក្នុងពន្ធនាគារនោះទេ។

[25] https://www.khmertimeskh.com/50809525/mother-nature-activists-last-chance-for-bail/
[26] https://www.khmertimeskh.com/50809525/mother-nature-activists-last-chance-for-bail/
[27 ]https://www.licadho-cambodia.org/articles/20200904/168/index.html One guard violently threw activist Seng Chanthorn to the road while blocking a protest.
https://www.rfa.org/english/news/cambodia/rebuffed-11132020175121.html
[28] Ministry of Women's Affairs and JICA, "Project on Gender Mainstreaming for Women's Economic Empowerment (PGM-WEE)" August 2020, p.13. There were 47,285 (16,693 girls) students in lower secondary schools and 22,526 (8166 female) in upper secondary schools in 2018-19.

យោងទៅតាមរបាយការណ៍ចេញ ផ្សាយនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុក ស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា លោកស្រី រ៉ូណា ស្មីត បានអោយដឹងថា ភាពចង្អៀតណែនក្នុងពន្ធនាគារនៅតែកើតមានឡើងទាំងនៅក្នុងមណ្ឌលស្តារនីតិសម្បទាគ្រឿងញៀនដែលគ្រប់គ្រងដោយ រដ្ឋាភិបាលនិងនៅតាមពន្ធនាគារ។ អត្រាផ្ទុកអ្នកជាប់ពន្ធនាគារជាមធ្យមសម្រាប់ពន្ធនាគារនៅក្នុងប្រទេសកម្ពុជា មានកម្រិតលើសពីសមត្ថភាពរហូតទៅដល់ ៣០០%។ លោកស្រី រ៉ូណា ស្មីត បានកត់សម្គាល់បន្ថែមទៀតថា តិចជាង១/៣ នៃអ្នកដែលជាប់ក្នុងពន្ធនាគារ បានទទួលសាលក្រមស្ថាពរហើយ និងអ្នកជាប់រផ្សេងៗទៀតគឺស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន (៣៥%) ឬកំពុងតែរង់ចាំនីតិវិធីបណ្តឹងឧទ្ធរណ៍ (៣៧%) [29] ។ រហូតមកដល់ចុងឆ្នាំ២០២០ ពន្ធនាគារតែមួយគត់នៅក្នុងប្រទេសសម្រាប់ដាក់ស្ត្រី និងអនីតិជន គឺមណ្ឌលកែប្រែ ម២ ស្ថិតនៅក្នុងកម្រិតលើសសមត្ថភាពប្រហែលដល់ទៅ ៤០០% [30]។ ក្នុងខែកុម្ភៈ ឆ្នាំ២០២១ ក្រសួងមហាផ្ទៃបានកត់សម្គាល់ថា អត្រាជាប់ពន្ធនាគារទូទាំងប្រទេស ស្ថិតនៅក្នុងកម្រិតមួយមានស្ថេរភាព” [31] ។

ការបន្តភាពចង្អៀតណែនក្នុងពន្ធនាគារមួយចំណែកធំ ដោយសារតែអត្រាកើនឡើងនៃការចាប់ខ្លួនក្នុងអំឡុងឆ្នាំ២០២០ តាមគោលការណ៍បង្ក្រាបគ្រឿងញៀនរបស់រាជរដ្ឋាភិបាល ដូចដែលបានបង្ហាញនៅក្នុងតួលេខថ្មីៗដែលបញ្ចេញដោយនាយកដ្ឋានប្រឆាំងគ្រឿងញៀនរបស់ក្រសួងមហាផ្ទៃ ក៏ដូចជាការខកខានជាបន្តបន្ទាប់ ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍សន្មត់ជាមុនថាគ្មានទោស ឬស្តង់ដារច្បាប់ផ្សេងៗទៀត ដែលទាក់ទងនឹងនីតិវិធីសុំនៅក្រៅឃុំ។

ស្របពេលជាមួយគ្នានេះដែរ ទោះបីជាមានការគំរាមកំហែងដោយសារតែជំងឺកូវីដ-១៩ ចំពោះប្រព័ន្ធពន្ធនាគារដែលមានភាពចង្អៀតណែនខ្លាំង ក៏ការទទួលបានសម្ភារៈអនាម័យ ទឹកស្អាត និងការរក្សាគម្លាតរាងកាយ នៅតែមិនមានចំនួនគ្រប់គ្រាន់ដែរ [32]។ រដ្ឋាភិបាលបានរាយការណ៍អំពីការណ៍ដែលបានធ្វើតេស្តកូវីដ-១៩ ទៅលើមនុស្សតិចជាង ១០០នាក់ ដែលកំពុងតែរស់នៅក្នុងពន្ធនាគារ ទោះបីជាមន្ត្រីពន្ធនាគារជាច្រើននាក់ ត្រូវបានធ្វើតេស្តរកឃើញថាវិជ្ជមានសម្រាប់វីរុសនេះក៏ដោយ។

ស្ត្រីមានផ្ទៃពោះ និងស្ត្រីជាម្តាយមួយចំនួនធំ ដែលជាប់ពន្ធនាគារជាមួយកូនៗរបស់ពួកគេ បន្តរស់នៅក្នុងពន្ធនាគារដោយមិនទទួលបានគ្រប់គ្រាន់នូវតម្រូវការជាមូលដ្ឋាន ដូចជាអាហារដែលមានជីវជាតិ ទឹកស្អាត ឬការថែទាំមុន និងក្រោយសម្រាលនោះទេ។ គិតមកត្រឹមខែមករា ឆ្នាំ២០២១ ក្មេងចំនួន ១០៦នាក់ កំពុងតែរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារចំនួន១៨ ដែលអង្គការលីកាដូធ្វើការតាមដាន [33] ។ នៅក្នុងខែមករា ឆ្នាំ២០២០ ទារកស្រីអាយុ៥ខែ ម្នាក់ដែលរស់នៅជាមួយម្តាយនៅមណ្ឌល ម២ បានស្លាប់នៅក្នុងមន្ទីរពេទ្យ ប៉ុន្តែមិនមានការស៊ើបអង្កេតឯករាជ្យណាមួយឱ្យបានពេញលេញចំពោះការស្លាប់របស់ទារក ដែលអាចបណ្តាលមកពីការធ្វេសប្រហែសពីមន្ត្រីពន្ធនាគារ និងបុគ្គលិកពេទ្យឡើយ។ ម្តាយរបស់នាងស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដោយសារតែមានថ្នាំមេតាហ្វេតាមីនដែលគិតជាលុយមានតម្លៃត្រឹមតែមួយម៉ឺនរៀល (២.៥ដុល្លារ) ប៉ុណ្ណោះ [34]។

[29] https://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session45/Documents/A_HRC_45_51_AEV.docx, para 40-41.
[30] https://www.licadho-cambodia.org/pressrelease.php?perm=466
[31] https://spcommreports.ohchr.org/TMResultsBase/DownLoadFile?gId=35939, page 2
[32] https://www.licadho-cambodia.org/pressrelease.php?perm=466
[33] LICADHO monitors 18 out of Cambodia’s 28 prisons.
[34] https://www.licadho-cambodia.org/pressrelease.php?perm=447

# អនុសាសន៍ដើម្បីអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន អនុសញ្ញា ស៊ី ដ ឱ្យកាន់តែប្រសើរ

ក្នុងខណៈដែលមិនមានការរំពឹងទុកថានឹងមានការអនុវត្តពេញលេញទៅលើអនុសាសន៍នានា ដែលមានចែងក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ី ដ រហូតដល់ពេលដែលរដ្ឋាភិបាលត្រូវដាក់របាយការណ៍បន្ទាប់ក្នុងកំឡុងខែវិច្ឆិកា ឆ្នាំ២០២៣ ក៏ដោយ រាជរដ្ឋាភិបាលគួរមានវិធានការចាំបាច់មួយចំនួនដែលត្រូវអនុវត្តក្នុងពេលបច្ចុប្បន្ននេះ ដើម្បីធានាថា សមិទ្ធផលទាំងនេះធ្វើឡើងទាន់ពេលវេលា។

ហេតុដូច្នេះ អង្គការ NGO-CEDAW និងដៃគូរបស់ខ្លួន សូមផ្តល់អនុសាសន៍ថា រដ្ឋាភិបាលគួរផ្តល់អាទិភាពក្នុងការចាត់វិធានការដូចខាងក្រោម ដើម្បីធ្វើឱ្យការអនុវត្តអនុសញ្ញា ស៊ី ដ នៅប្រទេសកម្ពុជាកាន់តែប្រសើរ៖

## ១

ទម្លាក់ចោលសេចក្តីព្រាងច្បាប់ ស្តីពីសណ្តាប់ធ្នាប់សាធារណៈ និងអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណែតជាតិ ដោយសារតែបទប្បញ្ញត្តិបែបនេះរំលោភបំពានទៅលើសេរីភាពក្នុងការសម្តែងមតិ និងសិទ្ធិទទួលបានឯកជនភាពរបស់ស្ត្រី ហើយចាំបាច់ត្រូវធ្វើការប៉ាន់ប្រមាណផលប៉ះពាល់ទៅលើយេនឌ័រ មុនអនុម័តច្បាប់ថ្មី។

## ២

បែងចែកផ្តល់ថវិកាជាតិឱ្យបានគ្រប់គ្រាន់សម្រាប់ការអនុវត្តផែនការសកម្មភាពជាតិលើកទី៣ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ព្រមទាំងគោលនយោបាយសមភាពយេនឌ័រឱ្យមានប្រសិទ្ធភាព។

## ៣

ធ្វើវិសោធនកម្មនិងពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពសំដៅលុបបំបាត់អំពើហិង្សាលើដៃគូស្និទ្ធស្នាល អំពើហិង្សាផ្លូវភេទទៅលើក្មេងស្រី និងរាល់ទម្រង់នៃអំពើហិង្សាផ្អែកលើយេនឌ័រ ជាពិសេស តាមរយៈការផ្តល់សេវាដែលមានការឆ្លើយតបតាមតម្រូវការរបស់ពួកគេ ដែលផ្តោតទៅលើសុខុមាលភាពផ្លូវកាយនិងផ្លូវចិត្តរបស់ជនរងគ្រោះ និងធានាឱ្យមានការទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះ។

## ៤

ដាក់ចេញនូវសកម្មភាពដើម្បីទប់ស្កាត់និងលុបបំបាត់រាល់ការបៀតបៀន រាល់អំពើហិង្សា និងរាល់ទម្រង់នៃការរើសអើងផ្អែកលើយេនឌ័រនៅក្នុងពិភពការងារ តាមរយៈការអនុម័តគោលនយោបាយជាតិរឹងមាំនិងតាមរយៈការផ្តល់សច្ចាប័នអនុសញ្ញា ILO ស្តីពីការលុបបំបាត់អំពើហិង្សាផ្អែកលើ យេនឌ័រ និងការបៀតបៀននៅពិភពការងារ (ILO C190)។

## ៥

បណ្តុះបណ្តាលរាល់មន្ត្រីសន្តិសុខដែលជ្រើសរើសដោយរដ្ឋាភិបាលនិងស្ថាប័នសាលាក្រុងខេត្ត ដោយរួមទាំងអ្នកគ្រប់គ្រង និងអ្នកចាត់ចែងផ្ទាល់អំពីរបៀបអន្តរកម្មជាមួយស្ត្រី តាមបែបអហិង្សា និងប្រកបដោយឥរិយាបថគិតគូរដល់យេនឌ័រ។

# ការវិវឌ្ឍន៍នៃការអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន អនុសញ្ញា ស៊ីដ ឆ្នាំ២០១៩

(ចំណាត់ថ្នាក់នេះ ផ្អែកទៅលើប្រព័ន្ធភ្លើងសញ្ញាចរាចរណ៍៖ ពណ៌ក្រហម = វិវឌ្ឍន៍តិចតួច/គ្មានការវិវឌ្ឍន៍, ពណ៌លឿង = មានការវិវឌ្ឍន៍មួយចំនួន, ពណ៌បៃតង = ការវិវឌ្ឍន៍ច្រើន

*សម្រាប់កថាខណ្ឌ 19, 25b, និង 47(d) ត្រូវដាក់ក្នុងរបាយការណ៍តាមដាន នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១

| កថាខណ្ឌ | ប្រធានបទ | សង្ខេប | ការវិវឌ្ឍន៍ចាប់តាំងពីឆ្នាំ ២០១៩ | ស្ថានភាព |
|---|---|---|---|---|
| 6 | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | ទទួលស្គាល់ថាស្ត្រីគឺជាកម្លាំងជំរុញមួយសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព | ស្ត្រីត្រូវបានចាត់ទុកជា "ឆ្អឹងខ្នង" នៃសេដ្ឋកិច្ច | |
| 9a | ក្របខណ្ឌច្បាប់ | និយមន័យនៃការរើសអើងនៅក្នុងច្បាប់ | គ្មាន | |
| 9b | ក្របខណ្ឌច្បាប់ | ការប៉ាន់ប្រមាណអំពីផលប៉ះពាល់យេនឌ័រជាលក្ខណៈប្រព័ន្ធទៅលើច្បាប់ | គ្មាន | |
| 11a | ការទទួលបានយុត្តិធម៌ | ជំនួយផ្នែកច្បាប់ដែលមានថវិការដ្ឋរយៈពេលវែង, តុលាការសាលាឧទ្ធរណ៍ថ្នាក់តំបន់ | មិនមានមូលនិធិរយៈពេលវែងសម្រាប់ជំនួយផ្នែកច្បាប់, ប្រព័ន្ធមិនទាន់មានលក្ខណៈទូលំទូលាយ។ សាលាឧទ្ធរណ៍ថ្មីៗបានចាប់ផ្តើមប្រតិបត្តិការនៅក្នុងខេត្តបាត់ដំបងនិងត្បូងឃ្មុំនៅខែឧសភា ឆ្នាំ២០២០ និងខេត្តព្រះសីហនុក្នុងខែកញ្ញាឆ្នាំ ២០២០ | |
| 11b | ការទទួលបានយុត្តិធម៌ | បញ្ឈប់ការប្រមាថមាក់ងាយក្នុងសង្គមចំពោះការរាយការណ៍អំពីការរំលោភបំពានទៅលើក្មេងស្រី | សកម្មភាពលើកកម្ពស់ការយល់ដឹង មានជាបន្តបន្ទាប់ | |
| 11c | ការទទួលបានយុត្តិធម៌ | ការផ្សព្វផ្សាយអំពីព័ត៌មាននៃការផ្តល់សំណងដំណោះស្រាយ | ការផ្សព្វផ្សាយមានកំហិត | |
| 11d | ការទទួលបានយុត្តិធម៌ | ប្រព័ន្ធយុត្តិធម៌ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ, ស្ត្រីមានចំនួនកាន់តែច្រើន, ការបណ្តុះបណ្តាលស្តីពីអនុសញ្ញា ស៊ីដ | មានការបណ្តុះបណ្តាលមួយចំនួន ប៉ុន្តែមិនបានទូលំទូលាយគ្រប់ជ្រុងជ្រោយនោះទេ | |
| 11e | ការទទួលបានយុត្តិធម៌ | ប្រព័ន្ធតុលាការដែលមានឯករាជ្យភាពនិងមិនលម្អៀង, ការស៊ើបអង្កេត និងការដាក់ទោសទណ្ឌទៅលើករណីនានា, ដោយរួមបញ្ចូលទាំងអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ | មិនមានការរីកចម្រើន គួរឱ្យកត់សម្គាល់ទេ | |

| កថាខណ្ឌ | ប្រធានបទ | សង្ខេប | ការវិវឌ្ឍន៍ចាប់តាំងពីឆ្នាំ ២០១៩ | ស្ថានភាព |
| --- | --- | --- | --- | --- |
| 11f | ការទទួលបានយុត្តិធម៌ | អាជ្ញាធរមានគណនេយ្យភាពចំពោះអំពើពុករលួយ | មិនមានសកម្មភាពបន្ថែមគួរឱ្យកត់សម្គាល់ទេ | 🔴 |
| 13a | វិវាទ | សំណងដល់ជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រក្នុងសម័យខ្មែរក្រហម | សេវានៅមានកម្រិតខ្លាំង | 🔴 |
| 13b | | ផែនការសកម្មភាពស្តីពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ SCR1325 | គ្មាន | 🔴 |
| 13c | វិវាទ | ស្ត្រីមានការចូលរួមពាក់ព័ន្ធនៅគ្រប់ដំណាក់កាលទាំងអស់នៃការកសាងសន្តិភាព | ស្ត្រីមានតំណាងល្អនៅក្នុងកងថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ, ប៉ុន្តែនៅថ្នាក់ជាតិមិនទាន់មានតំណាងល្អនោះទេ ឬនៅគ្រប់កម្រិតនៅឡើយនោះទេ | 🟡 |
| 15a | យន្តការថ្នាក់ជាតិ | ស្វ័យភាពរបស់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី | មិនទាន់មានស្វ័យភាពផ្នែកហិរញ្ញវត្ថុឬនយោបាយ | 🔴 |
| 15b | យន្តការថ្នាក់ជាតិ | ថវិកាជាតិសម្រាប់អនុវត្តគោលនយោបាយយេនឌ័រពេញលេញ | មូលនិធិមានកំហិត | 🔴 |
| 15c | យន្តការថ្នាក់ជាតិ | ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ | ការពន្យាពេលសម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងការធ្វើកែប្រែទៅលើសេចក្តីព្រាងទាំងអស់នោះ | 🟡 |
| 15d | យន្តការថ្នាក់ជាតិ | ការតាមដាននិងវាយតម្លៃប្រកបដោយប្រសិទ្ធភាពទៅលើគោលនយោបាយ សកម្មភាពយេនឌ័ររបស់ក្រសួង | មិនមានសម្រាប់ក្រសួងនោះទេ, ផែនការ នៅមានកម្រិត | 🔴 |
| 17 | ស្ថាប័នសិទ្ធិមនុស្ស | បង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិតាមគោលការណ៍ទីក្រុងប៉ារីស | គ្មាន | 🔴 |
| 19* | សង្គមស៊ីវិល | ការធានាអំពីសេរីភាពនៃការបញ្ចេញមតិ ការជួបជុំ និងសមាគម | មានការឃុំខ្លួននិងការចាប់ខ្លួនជារឿយៗ សម្រាប់ការផ្សព្វផ្សាយតាមហ្វេសប៊ុក សារព័ត៌មាន និងការជំទាស់តវ៉ា | 🔴 |
| 21a | វិធានការពិសេសបណ្តោះអាសន្ន | ការបែងចែកដីធ្លីឡើងវិញសម្រាប់ភាពជាម្ចាស់ដែលមានស្មើភាពគ្នាសម្រាប់ស្ត្រី | គ្មាន | 🔴 |
| 21b | វិធានការពិសេសបណ្តោះអាសន្ន | សន្តិសុខលំនៅស្ថានសម្រាប់ស្ត្រី | គ្មាន | 🔴 |

| កថាខណ្ឌ | ប្រធានបទ | សង្ខេប | ការវិវឌ្ឍន៍ចាប់តាំងពីឆ្នាំ ២០១៩ | ស្ថានភាព |
|---|---|---|---|---|
| 21c | វិធានការពិសេសបណ្តោះអាសន្ន | ឱកាសសេដ្ឋកិច្ចដែលមានកូតាត្រូវបានកែលម្អ | កម្ចី និងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅមានកម្រិត | |
| 23a | ផ្នត់គំនិត | យុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដើម្បីលុបបំបាត់ឥរិយាបថបែបបិតា-ធិបតេយ្យ | រដ្ឋាភិបាលនៅតែលើកកម្ពស់ផ្នត់គំនិតចាស់គំរិលទាំងឡាយថាជាវប្បធម៌ខ្មែរ | |
| 23b | ផ្នត់គំនិត | មធ្យោបាយជំនួសក្នុងការបង្រៀនអំពីយេនឌ័រដោយគ្មានច្បាប់ស្រី | មិនមានការផ្លាស់ប្តូរពិតប្រាកដនៅឡើយ | |
| 23c | ផ្នត់គំនិត | ការលើកកម្ពស់ឥរិយាបថវិជ្ជមានទៅលើសមភាពយេនឌ័រក្នុងចំណោមយុវជន | មិនមានការផ្លាស់ប្តូរពិតប្រាកដណាមួយ, ហើយពឹងផ្អែកជ្រុលទៅលើសង្គមស៊ីវិលក្នុងការធ្វើការងារនេះ | |
| 25a | អំពើហិង្សាផ្អែកលើយេនឌ័រ | ការប៉ាន់ប្រមាណផលប៉ះពាល់នៃវិធានការនិងការដោះស្រាយបុព្វហេតុជាឫសគល់ | មានការទទួលស្គាល់មួយចំនួនថា វិសមភាពយេនឌ័រគឺជាបុព្វហេតុឫសគល់ | |
| 25b | អំពើហិង្សាផ្អែកលើយេនឌ័រ | ការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយទៅលើច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ, ការធ្វើវិសោធនកម្មដើម្បីដាក់ទោសព្រហ្មទណ្ឌទៅលើរាល់អំពើ-ហិង្សាក្នុងគ្រួសារគ្រប់ទម្រង់, ការសម្រួល ការចេញដីកាការពារនិងការផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព | NAPVAW3 ចែងថាផែនការសកម្មភាពមួយនឹងត្រូវបានអនុម័តឡើងហើយថាមាត្រាមួយចំនួននឹងត្រូវធ្វើវិសោធនកម្ម | |
| 25c | អំពើហិង្សាផ្អែកលើយេនឌ័រ | កែលម្អសេវាចំបាច់ | កិច្ចប្រឹងប្រែងនៅមានកម្រិត ដើម្បីកែលម្អសេវាបញ្ជូន និងសេវាចាំបាច់ | |
| 25d | អំពើហិង្សាផ្អែកលើយេនឌ័រ | ប្រមូលទិន្នន័យអំពើហិង្សាផ្អែកលើយេនឌ័រជាលក្ខណៈប្រព័ន្ធ | មានការកែលម្អតិចតួច, ការរាយការណ៍/ករណីភាគច្រើនមិនត្រូវបានកត់ត្រានោះទេ | |
| 27a | ការជួញដូរ | ដោះស្រាយមូលហេតុឫសគល់នៃកង្វះឱកាសសេដ្ឋកិច្ច | កិច្ចប្រឹងប្រែងមានកម្រិតខ្លាំង | |
| 27b | ការជួញដូរ | កែលម្អការកំណត់អត្តសញ្ញាណនិងការបញ្ជូនសម្រាប់ជនរងគ្រោះ | មិនមានកិច្ចប្រឹងប្រែងថ្មីទេ | |
| 27c | ការជួញដូរ | ការធ្វើសមាហរណកម្មជនរងគ្រោះទៅក្នុងសង្គម | មិនមានកិច្ចប្រឹងប្រែងថ្មីទេ | |

| កថាខណ្ឌ | ប្រធានបទ | សង្ខេប | ការវិវឌ្ឍន៍ចាប់តាំងពីឆ្នាំ ២០១៩ | ស្ថានភាព |
|---|---|---|---|---|
| 27d | ការជួញដូរ | ការការពារស្ត្រីពីការទទួលខុសត្រូវ និងការការពារជនរងគ្រោះ | មិនមានកិច្ចប្រឹងប្រែងថ្មីទេ | 🟡 |
| 27e | ការជួញដូរ | ការដាក់ទណ្ឌកម្មទៅលើអ្នកជួញដូរ | មិនមានកិច្ចប្រឹងប្រែងថ្មីទេ | 🟡 |
| 27f | ការជួញដូរ | មិនប្រើប្រាស់ច្បាប់ប្រឆាំងការជួញដូរដោយខុសឆ្គង ទៅលើអ្នកដែលមិនមែនជាអ្នកជួញដូរ | ច្បាប់ស្ដីពីការជួញដូរត្រូវបានប្រើប្រាស់ខុសទៅលើស្ត្រីក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម | 🔴 |
| 29a | ពេស្យាចារ | វិសោធនកម្មច្បាប់ក្នុងការមិនដាក់ទោសព្រហ្មទណ្ឌទៅលើការងារផ្លូវភេទ | មិនមានកិច្ចប្រឹងប្រែង | 🔴 |
| 29b* | ពេស្យាចារ | ដាក់ទណ្ឌកម្មទៅលើអ្នកកេងប្រវ័ញ្ច | មានកិច្ចប្រឹងប្រែងមួយចំនួន | 🟡 |
| 29c | ពេស្យាចារ | ដោះស្រាយបុព្វហេតុឫសគល់ ដូចជាភាពក្រីក្រ តម្រូវការ និងវិសមភាព | កិច្ចប្រឹងប្រែងនៅមានកម្រិត | 🟡 |
| 29d | ពេស្យាចារ | ផ្តល់ការស្តារនីតិសម្បទា | អ្នកប្រកបរបរផ្លូវភេទត្រូវបានដាក់ទណ្ឌកម្ម ប៉ុន្តែមិនត្រូវបានផ្តល់ជំនួយឱ្យនោះទេ | 🔴 |
| 31a | ជីវិតសាធារណៈ | ការអនុម័តវិធានការពិសេសបណ្តោះអាសន្នដូចជាប្រព័ន្ធកូតា | មិនមានវិធានការជាផ្លូវការទេ | 🔴 |
| 31b | ជីវិតសាធារណៈ | បង្កើតបរិយាកាសអំណោយផលមួយសម្រាប់ស្ត្រី | មិនមានកិច្ចប្រឹងប្រែងគួរឱ្យកត់សម្គាល់ទេ | 🔴 |
| 33a | សញ្ជាតិ | ការទទួលបានសញ្ជាតិ ការអប់រំ ការងារ ការថែទាំសុខភាពនិងលំនៅឋានសម្រាប់ស្ត្រីជនជាតិវៀតណាមនិងខ្មែរក្រោម | មិនមានកិច្ចប្រឹងប្រែងគួរឱ្យកត់សម្គាល់ទេ | 🔴 |
| 33b | សញ្ជាតិ | សម្រួលក្នុងការធ្វើឯកសារអត្តសញ្ញាណប័ណ្ណនិងការចុះបញ្ជីសំបុត្រកំណើតដោយគ្មានការរើសអើងឯកសារ | គ្មានកិច្ចប្រឹងប្រែង | 🔴 |

| កថាខណ្ឌ | ប្រធានបទ | សង្ខេប | ការវិវឌ្ឍន៍ចាប់តាំងពីឆ្នាំ ២០១៩ | ស្ថានភាព |
|---|---|---|---|---|
| 33c | Nationality | ផ្តល់សច្ចាប័នអនុសញ្ញាចំនួន២ ស្តីពីភាពគ្មានរដ្ឋ | គ្មានកិច្ចប្រឹងប្រែង | |
| 35a | ការអប់រំ | បង្កើនការចូលរៀនមធ្យមសិក្សា, កាត់បន្ថយឧបសគ្គសម្រាប់ក្មេងស្រី | មានកិច្ចប្រឹងប្រែងមួយចំនួន ក្មេងស្រីក្នុងខេត្តកំពង់ធំនៅមានត្រឹម៣៥%ប៉ុណ្ណោះជាសិស្សនៅក្នុងមធ្យមសិក្សា | |
| 35b | ការអប់រំ | លើកទឹកចិត្តឱ្យស្ត្រីចូលរួមនៅក្នុងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា | កិច្ចប្រឹងប្រែងមួយចំនួន | |
| 35c | ការអប់រំ | ការបណ្តុះបណ្តាលអំពីយេនឌ័រឱ្យបានគ្រប់ជ្រុងជ្រោយសម្រាប់គ្រូ | មិនមានកិច្ចប្រឹងប្រែងគួរឱ្យកត់សម្គាល់ទេ | |
| 37a | ការងារ/មុខរបរ | កម្មករដែលធ្វើការក្រោមកិច្ចសន្យាមានថេរៈវេលាកំណត់ទទួលបានសេរីភាពសហជីពនិងអត្ថប្រយោជន៍មាតុភាព, ស្តារឲ្យប្រើប្រាស់ឡើងវិញនូវការកំណត់របស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលអំពីកិច្ចសន្យាមានរយៈពេលកំណត់ត្រឹមតែ២ឆ្នាំ | មិនមានកិច្ចប្រឹងប្រែងគួរឱ្យកត់សម្គាល់ទេ | |
| 37b | ការងារ/មុខរបរ | ការការពារវិស័យក្រៅប្រព័ន្ធដោយរួមបញ្ចូលទាំងកម្មការការងារតាមផ្ទះ ទៅក្នុងច្បាប់ការងារ | មិនមានកិច្ចប្រឹងប្រែងគួរឱ្យកត់សម្គាល់ទេ | |
| 37c | ការងារ/មុខរបរ | ការលើកកម្ពស់ការចែករំលែកភារកិច្ចជាឪពុកម្តាយ ការសម្រាកលំហែបិតុភាព | គ្មានកិច្ចប្រឹងប្រែង | |
| 37d | ការងារ/មុខរបរ | ការធ្វើច្បាប់ស្តីពីការបៀតបៀនផ្លូវភេទគ្រប់ជ្រុងជ្រោយ ដោយមានដំណោះស្រាយ | NAPVAW3 បានបញ្ចូលផែនការក្នុងការចំណាយរយៈពេលជាង៥ឆ្នាំ ដើម្បីបង្កើតគោលការណ៍ណែនាំស្តីពីការទប់ស្កាត់ការបៀតបៀនផ្លូវភេទ | |
| 37e | ការងារ/មុខរបរ | ធានាឱ្យមានការទទួលបានកម្រៃស្មើភាពគ្នាសម្រាប់ការងារដែលមានតម្លៃស្មើគ្នា ស្របតាមអនុសញ្ញា ILO C100 | គ្មានកិច្ចប្រឹងប្រែង | |
| 37f | ការងារ/មុខរបរ | ការពារកម្មការចំណាកស្រុកនៅក្រៅប្រទេស | មានកិច្ចប្រឹងប្រែងមួយចំនួន | |
| 37g | ការងារ/មុខរបរ | ផ្តល់សច្ចាប័នអនុសញ្ញា ILO 183 189 190 | គ្មានកិច្ចប្រឹងប្រែង | |

| កថាខណ្ឌ | ប្រធានបទ | សង្ខេប | ការវិវឌ្ឍន៍ចាប់តាំងពីឆ្នាំ ២០១៩ | ស្ថានភាព |
|---|---|---|---|---|
| 39a | សុខភាព | ការទទួលបានជាសាកលនៃសេវាថែទាំសុខភាពផ្លូវភេទនិងបន្តពូជ | ដើម្បីសម្រេចបាននូវការប្ដេជ្ញាចិត្តក្នុងការឆ្លើយតបទៅនឹងការថែទាំសុខភាពជាសកលមុនឆ្នាំ២០២៥ ប្រទេសកម្ពុជានៅត្រូវការធ្វើការងារច្រើន ជាពិសេសទាក់ទងជាមួយនឹងការបែងចែកថវិកាសម្រាប់សិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ |  |
| 39b | សុខភាព | លុបបំបាត់ការប្រមាថមាក់ងាយក្នុងសង្គមចំពោះការរំលូតកូននិងការប្រើប្រាស់មធ្យោបាយពន្យារកំណើត | ការប្រមាថមាក់ងាយក្នុងសង្គមទៅលើការរំលូតកូននៅតែមានកម្រិតខ្ពស់ ហើយមិនទាន់មានបញ្ចូលសូចនាករទៅក្នុងផែនការយុទ្ធសាស្ត្រស្ដីពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ឬនៅក្នុងនារីរតនៈ៥នៅឡើយទេ |  |
| 39c | សុខភាព | ដោះស្រាយតម្រូវការផ្នែកអាហារូបត្ថម្ភរបស់ស្ត្រីនៅក្នុងយុទ្ធសាស្ត្រនានា | ត្រូវបានដាក់បញ្ចូលនៅក្នុងនារីរតនៈ៥។ មានការប្ដេជ្ញាចិត្តខ្លាំងក្នុងការលុបបំបាត់កង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារនិងស្ត្រីមានផ្ទៃពោះក្នុងគោលនយោបាយនិងសកម្មភាពនានាតាមរយៈការអនុវត្តកម្មវិធីនិងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍និងអង្គការមិនមែនរដ្ឋាភិបាល |  |
| 39b | សុខភាព | ការទប់ស្កាត់មហារីកមាត់ស្បូន | មានកិច្ចប្រឹងប្រែងមួយចំនួន ប៉ុន្តែការពិនិត្យបឋមនៅមានកំហិតខ្លាំងណាស់ ហើយស្ត្រីជាច្រើនមិនបានដឹងអំពីហានិភ័យរបស់ខ្លួននោះទេ។ ប្រទេសកម្ពុជាមានករណីស្ត្រីចំនួនប្រហែល ១៥០០នាក់ដែលត្រូវបានធ្វើរោគវិនិច្ឆ័យក្នុងមួយឆ្នាំ ហើយអត្រាមរណៈមានកម្រិត៦០%ក្នុងចំណោមពួកគេ បើយោងតាមអង្គការសុខភាពពិភពលោក |  |
| 41 | ស្ត្រីជនបទ | ធ្វើនិយ័តកម្មអំពីស្ថាប័នមីក្រូហិរញ្ញវត្ថុនិងកែលម្អការទទួលបានកម្ចីការប្រាក់ទាប គាំទ្រដល់ធុរកិច្ចដែលគ្រប់គ្រងដោយស្ត្រី | កិច្ចប្រឹងប្រែងនៅមានកម្រិត |  |
| 43a | ការប្រែប្រួលអាកាសធាតុ | ដាក់បញ្ចូលស្ត្រីទៅក្នុងការបង្កើតគោលនយោបាយ | កិច្ចប្រឹងប្រែងនៅមានកម្រិត |  |

[35] https://www.phnompenhpost.com/national/who-seeks-end-cervical-cancer

| កថាខណ្ឌ | ប្រធានបទ | សង្ខេប | ការវិវឌ្ឍន៍ចាប់តាំងពីឆ្នាំ ២០១៩ | ស្ថានភាព |
|---|---|---|---|---|
| 43b | ការប្រែប្រួលអាកាសធាតុ | ចាប់យកទស្សនៈយេនឌ័រឱ្យបានច្បាស់លាស់នៅក្នុងគោល-នយោបាយ | មិនមានទស្សនៈយេនឌ័រច្បាស់លាស់ទេ | |
| 45a | ស្ត្រីជាប់ឃុំឃាំង | ប្រើប្រាស់វិធានការជំនួស ក្រៅពីការឃុំខ្លួន | មិនមានការរីកចម្រើន (កិច្ចប្រឹងប្រែងមួយចំនួនដើម្បីកាត់បន្ថយការកកស្ទះសំណុំរឿង ប៉ុន្តែពន្ធនាគារនៅតែមានភាពចង្អៀតណែនដោយសារតែអ្នកជាប់ឃុំបណ្ដោះអាសន្ន | |
| 45b | ស្ត្រីជាប់ឃុំឃាំង | ដោះស្រាយបុព្វហេតុឫសគល់និងផលប៉ះពាល់ទៅលើកុមារដោយសារការកាត់ទោស | គ្មានការវិវឌ្ឍន៍ | |
| 45c | ស្ត្រីជាប់ឃុំឃាំង | កាត់បន្ថយការភាពចង្អៀតណែន, ផ្តល់សេវាកម្ម តាមវិធានទីក្រុងបាងកក និងវិធានNelson Mandela | គ្មានការវិវឌ្ឍន៍ | |
| 47a | អ្នកពរពោះជំនួស | លុបចោលសេចក្តីសម្រេចខែតុលាឆ្នាំ២០១៦ ក្នុងការតម្រូវឱ្យអ្នកពរពោះជំនួស ក្នុងការចិញ្ចឹមកូនជាកូនខ្លួនឯង | មិនមានចេតនានៅក្នុងការលុបចោលនូវសេចក្តីសម្រេចចិត្តនេះទេ | |
| 47b* | អ្នកពរពោះជំនួស | ដោះស្រាយបុព្វហេតុឫសគល់តាមរយៈការកែលម្អឱកាសទទួលប្រាក់ចំណូលកាន់តែប្រសើរ | មិនមានកិច្ចប្រឹងប្រែងផ្តោតយកចិត្តទុកដាក់នោះទេ | |
| 47c | អ្នកពរពោះជំនួស | ធានាថាច្បាប់និងគោលនយោបាយនានាដោះស្រាយអតុល្យភាពអំណាចនៃអ្នកពរពោះជំនួស | មានភាពមិនច្បាស់លាស់, សេចក្តីព្រាងច្បាប់នៅកំពុងរង់ចាំ, មិនមានគោលនយោបាយថ្មី | |
| 47d | អ្នកពរពោះជំនួស | ច្បាប់មិនគួរដាក់ទោសព្រហ្មទណ្ឌទៅលើអ្នកពរពោះជំនួសទេ | មានភាពមិនច្បាស់លាស់ សេចក្តីព្រាងច្បាប់នៅកំពុងរង់ចាំ, មិនមានគោលនយោបាយថ្មី | |
| 49a | អាពាហ៍ពិពាហ៍ | វិធានការដែលបានផ្តោតនៅក្នុងការកាត់បន្ថយអត្រាអាពាហ៍ពិពាហ៍កុមារ | មានកិច្ចប្រឹងប្រែងមួយចំនួនក្នុងការលើកកម្ពស់ការយល់ដឹងនៅក្នុង NAPVAW3 | |
| 49b | អាពាហ៍ពិពាហ៍ | លុបចោលមាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី | មិនមានកិច្ចប្រឹងប្រែងនៅក្នុងការលុបចោល | |



**NGO-CEDAW is Cambodia's leading coalition dedicated to monitoring and promoting the implementation of the United Nations Convention on the Elimination of all forms of Discrimination Against Women (CEDAW). Founded in 1995, by Cambodian women activists energized by their participation in the Beijing World Conference on Women. NGO-CEDAW has grown from 9 founding organizational members to a coalition of 35 local member CSOs. Working with a wider network of 30 additional organizations, NGO-CEDAW gives voice to otherwise underrepresented groups of women and LGBTIQ.**

The work of NGO-CEDAW includes: research; advocacy and lobbying; awareness-raising and capacity-building; and information exchange among its members. Specific activities include an annual university debate, original art exhibitions, in-person advocacy at the UN, and workshops for local officials and community groups.


www.ngocedaw.org
ngocedaw.pnh@gmail.com
@TheCambodianNgoCommitteeOnCedaw


របាយការណ៍តាមដានការអនុវត្តអនុសញ្ញា ស៊ីដ ឆ្នាំ២០២០
សម្រាប់ប្រទេសកម្ពុជា